ISSN 1560-9197

# ពាណិជ្ជកម្មត្រីក្នុងស្រុក

## ករណីសិក្សានៃម៉ាឃីនីងត្រី
## ពីបឹងទន្លេសាបទៅក្រុងភ្នំពេញ

ឯកសារពិភាក្សាលេខ ២៩

យឹម ជា និង Bruce McKenney

ឯកសារ
ពិភាក្សា
លេខ ២៩

CAMBODIA DEVELOPMENT RESOURCE INSTITUTE

# ពាណិជ្ជកម្មត្រីក្នុងស្រុក

## ករណីសិក្សានៃម៉ាឃីនីងត្រីពីបឹងទន្លេសាបទៅក្រុងភ្នំពេញ

ឯកសារពិភាក្សាលេខ ២៩

យឹម ជា និង **Bruce McKenney**

វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

ខែធ្នូ ឆ្នាំ២០០៣

**Domestic Fish Trade: A Case Study of Fish Maketing from the Great Lake to Phnom Penh — Working Paper 29**

December 2003

*Yim Chea and Bruce McKenney*

© រក្សាសិទ្ធិឆ្នាំ២០០៣ វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

រក្សាសិទ្ធិគ្រប់យ៉ាង - គ្មានផ្នែកណាមួយនៃឯកសារនេះ ត្រូវបានចំលងទុក ឬផ្សព្វផ្សាយតាមទម្រង់ និងតាមមធ្យោបាយផ្សេងៗ ដូចជា អេឡិចត្រូនិក យន្តកម្ម ថតចម្លង... ។ល។ ដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីវិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជាឡើយ ។

**ISSN 1560 9812**

**ពាណិជ្ជកម្មត្រីក្នុងស្រុក: ករណីសិក្សានៃម៉ាឃីទីងត្រីពីបឹងទន្លេសាបទៅក្រុងភ្នំពេញ**

**ឯកសារពិភាក្សាលេខ ២៩**

ខែធ្នូ ឆ្នាំ២០០៣

យឹម ជា និង Bruce McKenney

ទស្សនៈទាំងឡាយនៅក្នុងឯកសារនេះ គឺជាគំនិតផ្ទាល់របស់អ្នកនិពន្ធ ។ ទស្សនៈទាំងនោះ មិនមែនជាទស្សនៈរបស់វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជាទេ ។

វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

ផ្ទះលេខ៥៦ ផ្លូវលេខ៣១៥ ខ័ណ្ឌទួលគោក ភ្នំពេញ កម្ពុជា (ប្រអប់សំបុត្រលេខ ៦២២ ភ្នំពេញ កម្ពុជា)

ទូរស័ព្ទ: (៨៥៥-២៣) ៨៨១-៧០១, ៨៨១-៩១៦, ៨៨៣-៦០៣ ទូរស័ព្ទ/ទូរសារ: (៨៥៥-២៣) ៨៨០-៧៣៤

អ៊ីមែល: cdri@camnet.com.kh **website:** http://www.cdri.org.kh

បកប្រែដោយ: អែម សូវ៉ានី

កែសម្រួល: យូ សិទ្ធីរិទ្ធ

បោះពុម្ពនៅប្រទេសកម្ពុជា ដោយរោងពុម្ពជប៉ុន ផ្ទះលេខ៧៤ ផ្លូវលេខ៩៩ សង្កាត់ផ្សារដើមថ្កូវ រាជធានីភ្នំពេញ

# មាតិកា


សេចក្តីសង្ខេប ........ ១

បញ្ជីអក្សរកាត់ ........ ៣

សេចក្តីថ្លែងអំណរគុណ ........ ៥

**ជំពូក ១. សេចក្តីផ្តើម** ........ ៧

១.១. កម្មវត្ថុនៃការសិក្សា ........ ៨

១.២. វិធីសាស្ត្រស្រាវជ្រាវ ........ ៨

**ជំពូក ២. រចនាសម្ព័ន្ធទីផ្សារ និងប្រតិបត្តិការពាណិជ្ជកម្មត្រី** ........ ១១

២.១. ប្រតិបត្តិការពាណិជ្ជកម្មទី១ ពីអ្នកនេសាទទៅពាណិជ្ជករ ........ ១២

២.២. ប្រតិបត្តិការពាណិជ្ជកម្មទី២ ពីពាណិជ្ជករទៅអ្នកលក់រាយ តាមរយៈអ្នកបែងចែក ........ ១៣

២.៣. ប្រតិបត្តិការពាណិជ្ជកម្មទី៣ ពីអ្នកលក់រាយទៅអតិថិជន ........ ១៦

**ជំពូក ៣. ចំណាយមាំឃីនិងត្រីសំខាន់ៗ និងឧបសគ្គ** ........ ១៩

៣.១. ការខូចខាត និងស្រកទំងន់ ........ ២១

៣.២. ការកាន់កាប់ផ្តាច់មុខនៃមណ្ឌលបែងចែកត្រី ........ ២៣

៣.៣. ប្រាក់កំរៃយកតាមផ្លូវពាណិជ្ជកម្ម ........ ២៤

៣.៤. ចំណាយដឹកជញ្ជូន និងទឹកកក ........ ២៥

៣.៥. ចំណាយហិរញ្ញប្បទាន ........ ២៦

**ជំពូក ៤. សេចក្តីសន្និដ្ឋាន និងអនុសាសន៍** ........ ២៧

**ឯកសារយោង** ........ ៣១

**បញ្ជីឯកសារពិភាក្សារបស់ វបសអ** ........ ៣៣

# សេចក្តីសង្ខេប

ត្រីទឹកសាបដែលគេអាចចាប់បានជាង ៤០០.០០០តោនក្នុងមួយឆ្នាំៗ និងមានការបរិភោគយ៉ាងច្រើននៅក្នុងស្រុក គឺជាទំនិញលក់ដូរដ៏សំខាន់បំផុតមួយក្នុងប្រទេសកម្ពុជា ។ ត្រីស្រស់ និងត្រីកែច្នៃ មានធ្វើពាណិជ្ជកម្មយ៉ាងទូលំទូលាយនៅក្នុងប្រទេសកម្ពុជា ដោយពាណិជ្ជកម្មភាគច្រើនមានប្រភពចេញពីបឹងទន្លេសាប ។ ម៉ាឃីទីងត្រី មានបញ្ហាប្រឈម និងដំណាក់កាលជាច្រើន រួមទាំងការស្តុកទុក, ការលើកដាក់រៀបចំ, ការប្រមូលទុកឱ្យបានច្រើនគ្រប់គ្រាន់សំរាប់ដឹកជញ្ជូន, ការដឹកជញ្ជូន, ការចរចាលក់, និងការរក្សាគុណភាពជាដើម ។ អប្រសិទ្ធិភាពខាងម៉ាឃីទីងធ្វើឱ្យចំណាយកើនឡើង ដែលអាចប៉ះពាល់ជាអវិជ្ជមានដល់ចំណូលរបស់អ្នកលក់ត្រី និងអ្នកនេសាទ ព្រមទាំងអ្នកផ្សេងទៀតដែលប្រកបការងារក្នុងវិស័យនេះ ។

ដើម្បីវាយតំលៃពីលក្ខខណ្ឌបច្ចុប្បន្ននៃការលក់ដូរត្រីទឹកសាប ការសិក្សានេះបានពិនិត្យពីពាណិជ្ជកម្មត្រីចាប់តាំងពីកន្លែងឡើងត្រីសំខាន់ៗពីរកន្លែងនៅបឹងទន្លេសាប រហូតដល់ទីផ្សារលក់រាយនៅក្រុងភ្នំពេញ ដែលជាផ្លូវពាណិជ្ជកម្មត្រីក្នុងស្រុកធំជាងគេបំផុត ។ ការស្រាវជ្រាវនេះផ្អែកលើប្រហែល ៦០បទសំភាសន៍ពាក់កណ្តាលរៀបរយ ធ្វើជាមួយអ្នកនេសាទ ពាណិជ្ជករ អ្នកបែងចែក ម្ចាស់មណ្ឌលបែងចែក អ្នកលក់រាយ និងមន្ត្រីរាជការ ។ លើសពីនេះទៀត មានការធ្វើដំណើរ "តាមរថយន្តដឹកត្រី" ពីរលើក ចាប់ពីកន្លែងឡើងត្រីរហូតដល់មណ្ឌលបែងចែក ដើម្បីសង្កេតផ្ទាល់ពីលក្ខខណ្ឌពាណិជ្ជកម្ម និងផ្ទៀងផ្ទាត់លើពត៌មានប្រមូលបាននៅក្នុងបទសំភាសន៍ ។

ម៉ាឃីទីងត្រីពីបឹងទន្លេសាបទៅភ្នំពេញ មានការលក់ដូរបីដំណាក់ គឺការលក់ពីអ្នកនេសាទទៅពាណិជ្ជករ ការលក់ពីពាណិជ្ជករទៅអ្នកលក់រាយតាមរយៈអ្នកបែងចែក និងការលក់ពីអ្នកលក់រាយទៅឱ្យអតិថិជន ។ អ្នកបែងចែកដើរតួនាទីចំបងនៅក្នុងរចនាសម្ព័ន្ធទីផ្សារដោយផ្តល់ហិរញ្ញវត្ថុសំរាប់ពាណិជ្ជកម្មត្រី ។ ពួកគេផ្តល់ទុនទៅឱ្យពាណិជ្ជករដើម្បីជួយទ្រទ្រង់ដល់ការទិញត្រី និងសកម្មភាពជំនួញផ្សេងៗ ហើយពាណិជ្ជករឱ្យអ្នកនេសាទខ្ចីបន្ត សំរាប់ទិញឧបករណ៍នេសាទ និងដោះស្រាយចំណាយផ្សេងៗ ។ កំចីទាំងនេះមានលក្ខខណ្ឌថា អ្នកនេសាទត្រូវលក់ផលត្រីចាប់បានទាំងអស់ទៅឱ្យពាណិជ្ជករ (ម្ចាស់ឥណទាន) ហើយពាណិជ្ជករត្រូវលក់ត្រីទិញបានទាំងអស់ទៅឱ្យអ្នកបែងចែក (ម្ចាស់ឥណទាន)របស់ខ្លួន និងបង់ "កំរៃជើងសារ" ឱ្យទៅអ្នកបែងចែកដែលតាមធម្មតាមានចំនួន ប្រហែល ៦-៨%នៃចំណូលលក់សរុប ។ ទំនាក់ទំនងចងគ្នាជាប់បែបនេះ ឃើញមានជាទូទៅក្នុងពាណិជ្ជកម្មត្រីពីបឹងទន្លេសាបទៅភ្នំពេញ ដោយអ្នកនេសាទភាគច្រើនជំពាក់បំណុលពាណិជ្ជករ ហើយពាណិជ្ជករភាគច្រើនជំពាក់បំណុលអ្នកបែងចែកត្រី ។

រចនាសម្ព័ន្ធទីផ្សារបច្ចុប្បន្ន ជួយឱ្យមានស្ថិរភាពដល់ការផ្គត់ផ្គង់ត្រីសំរាប់ពាណិជ្ជកម្ម ប៉ុន្តែបញ្ហាពឹងផ្អែកលើឥណទាន បានធ្វើឱ្យអ្នកនេសាទ និងពាណិជ្ជករ (ក្នុងកំរិតស្រាលជាង) មានការចាញ់ប្រៀប ។ អ្នកនេសាទមានជំហរខ្សោយ ក្នុងការចរចាលក់ផលត្រីដែលខ្លួនចាប់បាន ។ ពួកគេត្រូវតែលក់ឱ្យពាណិជ្ជករដែលខ្លួនជំពាក់បំណុល ។ បញ្ហាមួយទៀត គឺកង្វះតំលាភាពអំពីបន្ទុកចំណាយឥណទាន ។ ដោយសារការប្រាក់លើកំចីបានដាក់បង្កប់នៅក្នុងថ្លៃ (កំរិតទាប) ទិញត្រីពីអ្នកនេសាទ ឬក៏ជាចំណែកមួយនៃ "កំរៃជើងសារ" បង់ទៅឱ្យអ្នកបែងចែកលើរាល់ការលក់ត្រី ដូច្នេះបន្ទុកចំណាយពិតលើហិរញ្ញប្បទាននៅតែមិនច្បាស់

លាស់ ។ តាមមើលប្រហែលអ្នកឱ្យខ្ចីប្រាក់ (គឺអ្នកបែងចែក និងពាណិជ្ជករ) ឆ្លៀតយកចំណេញពីកង្វះតំលាភាពនេះ ដើម្បីបង្កើនចំណូលពីកំចីរបស់ពួកគេ ។

ពាណិជ្ជកម្មត្រីក៏ត្រូវប៉ះពាល់ដោយកត្តារាំងស្ទះជាច្រើនដែរ ។ ពាណិជ្ជករ និងអ្នកបែងចែករិះគន់ពីការបង់ប្រាក់កំរៃនៅមណ្ឌលបែងចែកផលនេសាទថា មានកំរិតខ្ពស់ពេកបើធៀបនឹងសេវាដែលផ្តល់ឱ្យមិនគ្រប់គ្រាន់ ។ ប៉ុន្តែដោយសារផ្លូវពាណិជ្ជកម្មសំខាន់និមួយៗ មានមណ្ឌលមួយសំរាប់បំរើឱ្យទីក្រុងភ្នំពេញ ដូច្នេះពួកគេគ្មានទីកន្លែង (ស្របច្បាប់) ណាផ្សេងដើម្បីធ្វើប្រតិបត្តិការពាណិជ្ជកម្មត្រីឡើយ ។ ពាណិជ្ជករខ្លះត្អូញត្អែរពីការត្រូវបង់ប្រាក់កំរៃក្រៅផ្លូវការនៅតាមផ្លូវពាណិជ្ជកម្ម ។ ការខូចខាត និងស្រកទំងន់ត្រី ជាការខាតបង់មួយធំគួរកត់សំគាល់ដល់ ១០-១៥% នៃទំងន់ដឹកជញ្ជូន (ឬប្រហែល ៥៥ដុល្លារ/តោន) ។ ការបាត់បង់តំលៃនេះកាន់តែធ្ងន់ធ្ងរថែមទៀត ដោយសារការអនុវត្តន៍ដាក់តាំងត្រីលក់គ្មានដាក់ទឹកកកនៅទីផ្សារ ។ អ្នកលក់រាយយកទឹកកកចេញ ពីព្រោះអ្នកទិញជាទូទៅតែងមានគំនិតថា បើមានទឹកកកគឺត្រីមិនស្រស់ល្អទេ ។ សរុបមក កត្តារាំងស្ទះទាំងនេះធ្វើឱ្យមានចំណាយម៉ាឃីទីងជាមធ្យមប្រហែល ៣០៨ដុល្លារ/តោន ពីបឹងទន្លេសាបទៅទីផ្សារលក់រាយទៅដល់ភ្នំពេញ ។ ជាលទ្ធផល កំរិតចំណេញនៃម៉ាឃីធីងសរុប គឺប្រហែល ៦៥-៧៥% នៃថ្លៃត្រីលក់រាយ ឯអ្នកនេសាទទទួលបានតែ ២៥-៣៥% ប៉ុណ្ណោះ ។

ដើម្បីកែលំអជីវភាពអ្នកនេសាទតាមរយៈការបង្កើនចំណូលពីការចាប់ត្រី ត្រូវអនុវត្តវិធានការមួយចំនួន ដើម្បីកាត់បន្ថយចំណាយម៉ាឃីទីង និងអប្រសិទ្ធិភាពផ្សេងៗ ។ ជាចុងក្រោយ របាយការណ៍នេះមានផ្តល់អនុសាសន៍មួយចំនួនសំរាប់ពិចារណា ។

១) បញ្ចូលការប្រកួតប្រជែងទៅក្នុងសេវាកម្មបែងចែកត្រី ដោយផ្តល់អាជ្ញាប័ណ្ណថែមទៀតឱ្យបើកមណ្ឌលបែងចែកផលនេសាទ ។

២) ធ្វើយុទ្ធនាការផ្លាស់ប្តូរគំនិតរបស់អ្នកទិញត្រីបរិភោគ អំពីការប្រើប្រាស់ទឹកកក និងភាពស្រស់នៃត្រីទឹកសាបនៅទីផ្សារលក់រាយ ។

៣) ធ្វើការស្រាវជ្រាវបច្ចេកទេសថែមទៀតពីបញ្ហាខូចគុណភាពត្រី នៅក្នុងប្រព័ន្ធម៉ាឃីទីងត្រី ពីកន្លែងនេសាទត្រីរហូតដល់មណ្ឌលបែងចែកផលនេសាទ ។

៤) កំណត់ពីភាពស្របច្បាប់នៃការបង់ប្រាក់កំរៃបច្ចុប្បន្ននៅតាមផ្លូវពាណិជ្ជកម្មត្រីក្នុងស្រុក និងលុបបំបាត់ការបង់ប្រាក់កំរៃណាដែលគ្មានមូលដ្ឋានច្បាប់ច្បាស់លាស់ ។

៥) ធ្វើការស្រាវជ្រាវបន្ថែមលើតួនាទីនៃប្រព័ន្ធផ្តល់ហិរញ្ញប្បទាន/ឥណទានក្រៅផ្លូវការនៅក្នុងវិស័យជលផល ។

# បញ្ជីអក្សរកាត់

| | |
|---|---|
| AFTA | ASEAN Free Trade Agreement / កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន |
| ASEAN អាស៊ាន | Association of South East Asian Nations/ សមាគមន៍ប្រជាជាតិអាស៊ីអគ្នេយ៍ |
| CDRI / វបសអ | Cambodia Development Resource Institute / វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា |
| DANIDA | Danish International Development Agency / ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិដាណឺម៉ាក |
| WTO | World Trade Organisation / អង្គការពាណិជ្ជកម្មពិភពលោក |
| គ.ក | គីឡូក្រាម |

# សេចក្តីថ្លែងអំណរគុណ

ក្រុមអ្នកនិពន្ធសូមសំដែងសេចក្តីដឹងគុណដល់បុគ្គលជាច្រើន រួមមាន អ្នកនេសាទ ពាណិជ្ជករ អ្នកបែងចែក អ្នកលក់រាយ ម្ចាស់មណ្ឌលបែងចែកផលនេសាទ មន្ត្រីនាយកដ្ឋានជលផល សាលាក្រុងភ្នំពេញ និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រាជធានីភ្នំពេញ ចំពោះការយល់ព្រមផ្តល់បទសំភាសន៏ និងការផ្តល់ពត៌មានលំអិតពីសកម្មភាពពាណិជ្ជកម្ម និងបញ្ហាខាងច្បាប់ និងបទប្បញ្ញត្តិផ្សេងៗ ។ បើសិនគ្មានការរួមចំណែករបស់បុគ្គលទាំងនេះទេ ការសិក្សានេះក៏មិនអាចដំណើរការបានដែរ ។ ក្រុមអ្នកនិពន្ធសូមថ្លែងអំណរគុណដល់ លោក ព្រំ តុលា ជាសហសេវិក និងជាអ្នកស្រាវជ្រាវនៃកម្មវិធីបរិស្ថាន និងធនធានធម្មជាតិនៅ វបសអ ចំពោះជំនួយទ្រទ្រង់ក្នុងការប្រមូលទិន្នន័យ និងការចុះស្រាវជ្រាវ ។ ក្រុមអ្នកនិពន្ធសូមថ្លែងអំណរគុណដល់ DANIDA ចំពោះការឧបត្ថម្ភថវិកាដល់កម្មវិធីបរិស្ថាន និងធនធានធម្មជាតិនៅ វបសអ ។ ក្រុមអ្នកនិពន្ធសូមថ្លែងអំណរគុណយ៉ាងច្រើន ដល់បណ្ឌិត K.A.S Murshid នាយកស្រាវជ្រាវ និងលោកស្រី Eva Mysliwiec នាយិកា វបសអ ចំពោះការជួយផ្តល់មតិយោបល់ និងការគាំទ្រដ៏មានតំលៃ ។

ភ្នំពេញ, ខែ វិច្ឆិកា ឆ្នាំ ២០០៣

*Bruce McKenney* និង យឹម ជា

វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

# ជំពូក ១

# សេចក្តីផ្តើម

ក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ ប្រទេសកម្ពុជាបានឈានទៅមុខគួរឱ្យកត់សំគាល់ក្នុងការបង្កើនកំរិតសមាហរណកម្មរបស់ខ្លួនទៅក្នុងទីផ្សារក្នុងតំបន់ និងអន្តរជាតិ ហើយសំខាន់បំផុតគឺតាមរយៈកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន (AFTA) និងការចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក (WTO) ។ ស្របគ្នាជាមួយដំណើរការនេះ គោលនយោបាយអភិវឌ្ឍន៍សេដ្ឋកិច្ច បានផ្តោតកាន់តែខ្លាំងលើការកែលំអលក្ខខណ្ឌពាណិជ្ជកម្ម និងបរិយាកាសវិនិយោគ ។ ជាមូលដ្ឋាននៃវិធានការនេះ ក្រសួងពាណិជ្ជកម្មកំពុងលើកកំពស់យុទ្ធសាស្ត្រ "ពាណិជ្ជកម្មអំណោយផលដល់អ្នកក្រ" សំដៅនាំយកឱកាសល្អៗខាងពាណិជ្ជកម្ម និងការនាំចេញទៅដល់អ្នកក្រីក្រនៅជនបទ ។ ដើម្បីឱ្យកិច្ចប្រឹងប្រែងនេះទទួលបានជោគជ័យ សមាហរណកម្មទីផ្សារក្នុងស្រុក និងប្រសិទ្ធិភាពខាងពាណិជ្ជកម្ម ចាំបាច់ត្រូវកែលំអថែមទៀត ជាពិសេសនៅក្នុងតំបន់ជនបទ និងចេញពីតំបន់ជនបទ ។

ត្រីទឹកសាបជាមុខទំនិញកម្ពុជាមួយមានការលក់ដូរមមាញឹកបំផុតគឺ លក់រស់ក្នុងធុង លក់ស្រស់ដោយដាក់ទឹកកក និងលក់ជាផលិតផលកែច្នៃច្រើនប្រភេទ ។ ចេញពីបឹងទន្លេសាបដែលមានផលត្រីចាប់បានក្នុងមួយឆ្នាំៗជាង ២00.000តោនត្រីបានបញ្ជូនទៅលក់ពាសពេញប្រទេស ក្នុងនេះផ្លូវពាណិជ្ជកម្មក្នុងស្រុកដែលធំបំផុតគឺផ្លូវទៅកាន់ក្រុងភ្នំពេញ (Van Zalinge *et al* 2000) ។ ក្នុងម៉ាឃីទីងត្រី មានបញ្ហាប្រឈម និងដំណាក់កាលជាច្រើនរួមទាំងការស្តុកទុក ការលើកដាក់រៀបចំ ការប្រមូលទុកឱ្យបានច្រើនគ្រប់គ្រាន់សំរាប់ដឹកជញ្ជូន ការដឹកជញ្ជូន ការចរចាលក់ និងការរក្សាគុណភាពជាដើម ។ អប្រសិទ្ធិភាពក្នុងការងារទាំងនេះធ្វើឱ្យចំណាយកើនឡើង ដែលអាចប៉ះពាល់អវិជ្ជមានដល់ចំណូលរបស់អ្នកលក់ត្រី និងអ្នកនេសាទ ព្រមទាំងអ្នកផ្សេងទៀតដែលប្រកបការងារក្នុងវិស័យនេះ ។ នៅពេលចំណាយម៉ាឃីទីងកើនឡើង អ្នកលក់ត្រីអាចត្រូវផ្ទេរបន្ទុកចំណាយនេះមួយចំនួន ទៅអ្នកផ្សេងទៀតនៅក្នុងបណ្តាញម៉ាឃីទីង (រួមទាំងអ្នកនេសាទ តាមការបន្ទាបថ្លៃទិញត្រីចូល) ។ ផ្ទុយទៅវិញ នៅពេលប្រសិទ្ធិភាព និងលក្ខខណ្ឌម៉ាឃីទីងបានប្រសើរឡើង អ្នកលក់ត្រី អ្នកនេសាទ និងអ្នកផ្សេងទៀតនៅក្នុងវិស័យនេះ អាចទទួលបានផលចំណេញពីការកាត់បន្ថយបន្ទុកចំណាយ ។

ដើម្បីជួយបង្កើនការយល់ដឹងពីប្រសិទ្ធិភាព និងចំណាយម៉ាឃីទីង, ការសិក្សានេះពិនិត្យលើពាណិជ្ជកម្មត្រី ចាប់តាំងពីកន្លែងឡើងត្រីចំបងៗពីរនៅបឹងទន្លេសាប រហូតដល់ទីផ្សារលក់រាយនៅភ្នំពេញ ។ ថ្វីបើផ្លូវពាណិជ្ជកម្មនេះគ្រាន់តែជាផ្លូវមួយក្នុងចំណោមផ្លូវជាច្រើនដែលត្រីត្រូវបានធ្វើម៉ាឃីទីងនៅកម្ពុជាក្តី ប៉ុន្តែ វាជាផ្លូវដ៏សំខាន់ជាងគេបំផុត ។ បរិមាណត្រីដ៏ច្រើនបានធ្វើពាណិជ្ជកម្មតាមផ្លូវខាងលើជារៀងរាល់ឆ្នាំ ។ ឯកសារនេះសិក្សាពីបញ្ហាម៉ាឃីទីងមួយចំនួន រួមទាំង រចនាសម្ព័ន្ធទីផ្សារសំរាប់ពាណិជ្ជកម្ម តួនាទីហិរញ្ញប្បទាននិងឥណទាន ព្រមទាំងប្រតិបត្តិការ ឧបសគ្គចំបងៗ នៃម៉ាឃីទីងត្រី ។ ពត៌មាន និងទិន្នន័យនានាប្រមូលបានពីជិត ៦0បទសំភាសន៍ពាក់កណ្តាលរៀបរយធ្វើជាមួយអ្នកនេសាទ, ពាណិជ្ជករ អ្នកបែងចែក ម្ចាស់មណ្ឌលបែងចែក អ្នកលក់រាយ និងមន្ត្រីរាជការ ។ លើសពីនេះទៀតអ្នកស្រាវជ្រាវបានធ្វើដំណើរ "តាមរថយន្តដឹកត្រី" ពីរលើកចាប់ពីកន្លែងឡើងត្រីរហូតដល់មណ្ឌលបែងចែក ដើម្បីសង្កេតផ្ទាល់ពីលក្ខខណ្ឌពាណិជ្ជកម្ម និងផ្ទៀងផ្ទាត់ទៅលើពត៌មានដែលប្រមូលបាននៅក្នុងបទសំភាសន៍ ។



អ្នកលក់រាយកំពុងបង់ប្រាក់ទិញត្រីឱ្យពាណិជ្ជករ នៅមណ្ឌលបែងចែកផលនេសាទច្រាំងចំរេះ

## ១.១. កម្មវត្ថុនៃការសិក្សា

កម្មវត្ថុនៃការសិក្សានេះរួមមាន ការស្វែងយល់ពីការរាំងស្ទះ ចំណាយប្រតិបត្តិការពាណិជ្ជកម្ម និងកិច្ចអន្តរាគមន៍ទៅលើម៉ាឃីទីងនៅក្នុងពាណិជ្ជកម្មត្រីពីបឹងទន្លេសាបទៅភ្នំពេញ ការគណនាពីចំណាយលើការរាំងស្ទះទាំងនេះ និងការផ្តល់អនុសាសន៍ខាងគោលនយោបាយដែលគាំទ្រដល់គោលដៅរបស់រដ្ឋាភិបាល ដើម្បីបង្កើនប្រសិទ្ធិភាព ពាណិជ្ជកម្ម និងកាត់បន្ថយភាពក្រីក្រ ។ ការស្រាវជ្រាវនេះបានធ្វើឡើងដើម្បីបំពេញបន្ថែមលើកិច្ចប្រឹងប្រែងដ៏ធំមួយ ដើម្បីពិនិត្យពីលក្ខខណ្ឌទីផ្សារសំរាប់ការនាំចេញត្រីពីបឹងទន្លេសាបទៅប្រទេសថៃ (Yim and McKenney 2003) ។ ក្នុងគំនិតនេះការសិក្សានឹង:

អធិប្បាយពីរចនាសម្ព័ន្ធទីផ្សារសំរាប់ពាណិជ្ជកម្មត្រី ពីបឹងទន្លេសាបទៅភ្នំពេញ (តាមផ្លូវជាតិលេខ៥) រួមទាំងប្រតិបត្តិការពាណិជ្ជកម្មសំខាន់ៗ បញ្ហាស្តុកនិងម៉ាឃីទីងត្រី ក្របខ័ណ្ឌច្បាប់/បទប្បញ្ញត្តិនិងតួនាទីឥណទាន (ជំពូកទី២) ។

វាយតំលៃពីបញ្ហាប្រឈមចំបងៗចំពោះពាណិជ្ជកម្មត្រីតាមច្រកក្នុងស្រុកនេះ និងគណនាពីបន្ទុកចំណាយប្រតិបត្តិការពាណិជ្ជកម្ម ។ ប៉ាន់ប្រមាណចំណាយ ប្រាក់កំរៃ ចំណេញ និងកំរិតចំណេញម៉ាឃីទីង (ជំពូកទី ៣) ។

ផ្តល់អនុសាសន៍ខាងគោលនយោបាយ សំដៅកែលំអលក្ខខណ្ឌធ្វើពាណិជ្ជកម្មត្រី (ជំពូក ៤) ។

## ១.២. វិធីសាស្ត្រស្រាវជ្រាវ

ការស្រាវជ្រាវសំរាប់ការសិក្សានេះបានផ្តោតលើសកម្មភាពពាណិជ្ជកម្មត្រីពីបឹងទន្លេសាបទៅភ្នំពេញតាមផ្លូវជាតិលេខ ៥ ដែលជាផ្លូវពាណិជ្ជកម្មដ៏ចំបងមួយ ។ ដោយប្រើបញ្ជីសំនួរបានរៀបចំរួច វបសអ បានធ្វើជិត ៦០បទសំភាសន៍ពាក់កណ្តាលរៀបរយជាមួយអ្នកនេសាទ(២៩នាក់) ពាណិជ្ជករ(១១នាក់) អ្នកបែងចែក(៧នាក់) ម្ចាស់មណ្ឌលបែងចែកម្នាក់ អ្នកលក់រាយ (១១នាក់) និងមន្ត្រីរដ្ឋាភិបាល(២នាក់) នៅរវាងខែធ្នូ ឆ្នាំ២០០២ និងសីហា ឆ្នាំ២០០៣ ។ អ្នកនេសាទនិងពាណិជ្ជករទាំងអស់ ត្រូវបានសំភាសនៅខែធ្នូ ឆ្នាំ២០០២ នៅកន្លែងឡើងត្រីពីរនៅបឹងទន្លេសាបគឺ កំពង់លួង នៅខេត្តពោធិសាត់ និងទីរួមខេត្តកំពង់ឆ្នាំង (ក្រាហ្វិក ១.១) ។ អ្នកបែងចែក ៧នាក់ ជ្រើសរើសតាមវិធីចៃដន្យពីក្នុងចំណោម១៩នាក់ និងម្ចាស់មណ្ឌលផងដែរ ត្រូវបានធ្វើសំភាសន៍នៅមណ្ឌលបែងចែកផលនេសាទច្រាំងចំរេះ ដែលជាមណ្ឌលធំជាងគេបំរើឱ្យទីក្រុងភ្នំពេញ ។ អ្នកលក់រាយ ១១នាក់ ជ្រើសពីក្នុងចំនោម ៦០នាក់ នៅផ្សារអូឬស្សី និងផ្សារធំថ្មី ក៏ត្រូវបានសំភាសន៍ផងដែរ ។ បទសំភាសន៍ផ្តោតលើការរក ឱ្យឃើញ និងការវាយតំលៃពីរចនាសម្ព័ន្ធទីផ្សារ សំរាប់ពាណិជ្ជកម្មត្រី ចំណាយនិងបញ្ហាប្រឈមខាងម៉ាឃីទីង បទប្បញ្ញត្តិបង្កការរាំងស្ទះ និងបញ្ហាឥណទាន ។ ដោយទទួលស្គាល់ថា ថ្លៃត្រីប្រែប្រួលខ្លាំងណាស់ ដូច្នេះបទសំភាសន៍នេះពុំមានបំនងប្រមូលពត៌មានពីថ្លៃត្រី និងប៉ាន់ស្មានកំរិតចំណេញម៉ាឃីទីងទេ ។

ក្រាហ្វិក ១.១ ផែនទីផ្លូវពាណិជ្ជកម្ម និងកន្លែងឡើងត្រី ដែលបានសិក្សា



ដើម្បីបានឃើញ "រូបភាព" នៃកំរិតចំណេញម៉ាឃីទីងពិត (និងផ្ទៀងផ្ទាត់ពត៌មានបានពីបទសំភាសន៍) មានការធ្វើដំណើរ "តាមរថយន្តដឹកត្រី" ពីរលើកនៅថ្ងៃទី១២-១៣ និង ២៨-២៩ ធ្នូ ២០០២ ។ អ្នកស្រាវជ្រាវបានរួមដំណើរ ជាមួយរថយន្តដឹកត្រី និងពាណិជ្ជករ ពីកន្លែងឡើងត្រីនៅកំពង់លួងខេត្តពោធិសាត់ រហូតដល់មណ្ឌលបែងចែកផលនេសាទច្រាំងចំរេះនៅភ្នំពេញ ។ បន្ទាប់មក អ្នកស្រាវជ្រាវបានធ្វើដំណើរពីមណ្ឌលបែងចែកទៅដល់ទីផ្សារលក់រាយ ដើម្បីស្រង់ពត៌មានពីថ្លៃត្រី តាមប្រភេទត្រីជ្រើសរើសមួយចំនួន ។ បន្ថែមលើពត៌មានអំពីកំរិតចំណេញម៉ាឃីទីង, ដំណើរតាមរថយន្តដឹកត្រីទាំងនេះ បានជួយកែលំអគុណភាពទិន្នន័យតាមរយៈការបង្កើនទំនុកចិត្តរវាងពាណិជ្ជករ និងអ្នកស្រាវជ្រាវ ដោយអនុញ្ញាតឱ្យសង្កេតឃើញផ្ទាល់ពីលក្ខខណ្ឌពាណិជ្ជកម្ម, កត់ត្រាបន្ថែម និងផ្ទៀងផ្ទាត់លើ ចំណាយការបង់ប្រាក់នានា និងពត៌មានផ្សេងទៀត ។

គួរកត់សំគាល់ផងដែរពីចំណុចខ្វះខាតមួយចំនួន ។ ទីមួយៈ ការសិក្សានេះគ្របដណ្តប់តែលើពាណិជ្ជកម្មត្រីស្រស់ឆ្លងកាត់តាមផ្លូវពាណិជ្ជកម្មសំខាន់តែមួយផ្លូវពីបឹងទន្លេសាបទៅទីក្រុងភ្នំពេញ ។ ពាណិជ្ជកម្មផលនេសាទផ្សេងទៀត (ត្រីកែច្នៃ និងត្រីទឹកប្រៃ) មកពីកន្លែងឡើងត្រី និងកន្លែងនេសាទសំខាន់ៗឯទៀត (បឹងទន្លេសាប និងកន្លែងផ្សេង) និង/ឬ ផ្លូវពាណិជ្ជកម្មផ្សេងទៀត (ពីបឹងទន្លេសាប តាមទូក តាមដងទន្លេមេគង្គ) មិនបានលើកមកសិក្សាទេ ។ ធនធានមានកំរិតពុំអនុញ្ញាតឱ្យមានការសិក្សាធំទូលាយជាងនេះទេ ។

ឧបសគ្គខាងធនធាននេះក៏មិនអនុញ្ញាតឱ្យមានសិក្សាលំអិតលើកំរិតចំណេញម៉ាឃីទីងដែរ ។ ដូចបានកត់សំគាល់នៅខាងលើ ការធ្វើដំណើរ "តាមរថយន្តដឹកត្រី" គ្រាន់តែផ្តល់ "រូបភាព" ខ្លះនៃសកម្មភាពពាណិជ្ជកម្មត្រីក្នុងរដូវនេសាទ ដោយផ្តល់លទ្ធភាពឱ្យធ្វើការវាយតំលៃពីចំណាយម៉ាឃីទីងលើត្រីជ្រើសរើសបីប្រភេទក្នុងថ្ងៃជាក់លាក់មួយ ពីកន្លែងឡើងត្រីរហូតដល់អ្នកប្រើប្រាស់នៅទីក្រុងភ្នំពេញ ។ ថ្វីបើកំរិតចំណូលទាំងនេះ បានបង្ហាញពីចំណូលសុទ្ធរបស់តួអង្គនានាក្នុងខ្សែរយៈម៉ាឃីទីង ប៉ុន្តែចំណូលនេះវា ឡើងចុះយ៉ាងច្រើនតាមពេលខុសៗគ្នាក្នុងឆ្នាំនិមួយៗ ។ ប៉ុន្តែគួរបញ្ជាក់ជាសំខាន់ថា ចំណាយម៉ាឃីទីង (ដឹកជញ្ជូន ទឹកកក កំលាំងពលកម្ម ប្រាក់កំរៃ...) ប្រែប្រួលតិចជាង ហើយការវិភាគលើចំណាយទាំងនេះ គឺជាចំណុចសំខាន់សំរាប់កែលំអលក្ខខណ្ឌធ្វើពាណិជ្ជកម្ម ។

# ជំពូក ២

# រចនាសម្ព័ន្ធទីផ្សារ និងប្រតិបត្តិការពាណិជ្ជកម្មត្រី

នៅទូទាំងប្រទេសកម្ពុជា ត្រីភាគច្រើនបានលក់ចេញពីកន្លែងឡើងត្រីនៅតាមភូមិបណ្តែតទឹក ឬកន្លែងផែនៅជុំវិញបឹងទន្លេសាប និងតាមដងទន្លេសាប ។ ត្រីត្រូវបានលក់រស់ដោយដាក់ក្នុងធុងដែកមានទឹក លក់ស្រស់ដាក់ក្នុងទឹកកក និងលក់ជាផលិតផលកែច្នៃច្រើនប្រភេទ ។ ចំពោះពាណិជ្ជកម្មត្រីក្នុងស្រុកភាគច្រើន អ្នកលក់រាយទិញត្រីពីពាណិជ្ជករ ឬទៅទិញដោយផ្ទាល់នៅកន្លែងឡើងត្រីពីអ្នកនេសាទ ។ ប៉ុន្តែមណ្ឌលបែងចែកផលនេសាទដើរតួនាទីដ៏សំខាន់ក្នុងពាណិជ្ជកម្មផ្គត់ផ្គង់ត្រីទៅទីក្រុង ជាពិសេសនៅបាត់ដំបង និងភ្នំពេញ ។ ចំពោះពាណិជ្ជកម្មត្រីនៅក្រុងភ្នំពេញ មានបទបញ្ជារបស់សាលាក្រុងភ្នំពេញ តំរូវឱ្យរថយន្តដឹកត្រីឈប់និងលក់ត្រីនៅមណ្ឌលបែងចែកផលនេសាទមានអាជ្ញាប័ណ្ណ ចំងាយពីរបីគីឡូម៉ែត្រខាងក្រៅក្រុងភ្នំពេញ ដើម្បីកាត់បន្ថយការស្ទះចរាចរ ។

ជំពូកនេះពិនិត្យពីរចនាសម្ព័ន្ធទីផ្សារសំរាប់ពាណិជ្ជកម្មផ្គត់ផ្គង់ត្រីទៅទីក្រុងភ្នំពេញ ចាប់តាំងពីកន្លែងឡើងត្រីពីរកន្លែងនៅបឹងទន្លេសាបគឺ កំពង់លួងនៅខេត្តពោធិសាត់ និងទីរួមខេត្តកំពង់ឆ្នាំង ដោយផ្តោតលើអ្នកចូលរួម និងប្រតិបត្តិការពាណិជ្ជកម្មសំខាន់ៗ សេវាកម្ម និងពត៌មានទីផ្សារ ព្រមទាំងតួនាទីនៃហិរញ្ញប្បទាន និងឥណទាន ។ ដូចមានបង្ហាញក្នុងក្រាហ្វិក២.១ ខ្សែសង្វាក់សំរាប់ផ្លូវពាណិជ្ជកម្មត្រី ជាទូទៅទាក់ទងទៅនឹងការលក់ត្រីពីអ្នកនេសាទ ទៅដល់ពាណិជ្ជករ (ប្រតិបត្តិការពាណិជ្ជកម្មទី១), ពីពាណិជ្ជករទៅអ្នកលក់រាយតាមរយៈអ្នកបែងចែក (ប្រតិបត្តិការពាណិជ្ជកម្មទី២) និងពីអ្នកលក់រាយទៅអតិថិជន (ប្រតិបត្តិការពាណិជ្ជកម្មទី៣) ។ ប្រតិបត្តិការនិមួយៗដូចខាងលើត្រូវបានវាយតំលៃ លំអិតនៅខាងក្រោម ។

ក្រាហ្វិក ២.១. ខ្សែសង្វាក់ទីផ្សារសំរាប់ពាណិជ្ជកម្មៈ ពីបឹងទន្លេសាប ទៅភ្នំពេញ



## ២.១. ប្រតិបត្តិការពាណិជ្ជកម្មទី១ ពីអ្នកនេសាទទៅពាណិជ្ជករ

ក្នុងពេញមួយឆ្នាំៗ មានពាណិជ្ជកររាប់រយនាក់ទិញត្រីពីអ្នកនេសាទរាប់ពាន់នាក់នៅកន្លែងឡើងត្រីកំពង់លួង និងទីរួម ខេត្តកំពង់ឆ្នាំង ។ ថ្វីបើសកម្មភាពលក់ត្រីទទួលរងឥទ្ធិពលអំពីបរិមាណត្រីចាប់បាន (រយៈពេលត្រីសំបូរ និងមិនសំបូរ) តាមពេលខុសៗគ្នាក្នុងមួយឆ្នាំៗក្តី ប៉ុន្តែអ្នកនេសាទ និងពាណិជ្ជកររាយការណ៍ថា បទបញ្ញាបិទរដូវនេសាទមានឥទ្ធិពលតិចតួចលើពាណិជ្ជកម្មត្រី ដោយសារកង្វះវិធានការពង្រឹងការអនុវត្តន៏ច្បាប់[១] ។ អ្នកនេសាទដែលបានឆ្លើយនឹងសំភាសន៏ បានចេញទៅចាប់ត្រីប្រហែល ២០០-២៥០ថ្ងៃ/ឆ្នាំ ហើយពាណិជ្ជកររាយការណ៍ថាបានជួញដូរត្រីស្ទើរតែរាល់ថ្ងៃ ។ មិនឃើញមានតួនាទីខុសប្លែកគ្នាតាមភេទទេ: ទាំងបុរស និងស្ត្រី មានប្រកបរបរជាអ្នកនេសាទ និងពាណិជ្ជករ ហើយជារឿយៗក្នុងលក្ខណៈជាអង្គភាពគ្រួសារដែលមានប្តី ប្រពន្ធ កូន និងសាច់ញាតិ ។



អ្នកនេសាទកំពុងដោះមងនៅទន្លេសាប ខេត្តកំពង់ឆ្នាំង

ពាណិជ្ជករជាតួយ៉ាងម្នាក់ ទិញត្រីជាទៀងទាត់ពីអ្នកនេសាទប្រហែលពី ៣០-៧០នាក់ ។ ដោយប្រើទូក ធុងជ័រ និងទឹកកក ពាណិជ្ជករអាចប្រមូលត្រីអស់ពេលច្រើនថ្ងៃ ទើបបានច្រើនគ្រប់គ្រាន់សំរាប់ដឹកចេញទៅកាន់មណ្ឌលបែងចែក ។ នៅរដូវមិនសំបូរត្រី បើសិនពាណិជ្ជករត្រូវការដឹកត្រីចេញ ប៉ុន្តែមិនទាន់មានត្រីផ្ទុកបានពេញមួយរថយន្ត ពួកគេអាចជួលរថយន្តដឹកត្រីរួមគ្នា ។ ពាណិជ្ជករភាគច្រើនដឹកត្រីនៅពេលយប់ ដើម្បីអាចមកដល់មណ្ឌលបែងចែកត្រីទីក្រុងភ្នំពេញនៅទៀបភ្លឺ (ប្រហែលម៉ោង ២ព្រឹក) ដែលជាកន្លែងគេអាចរើត្រីលក់បន្តឱ្យអ្នកលក់រាយដែលយកវាទៅលក់នៅផ្សារឱ្យអតិថិជននៅពេលព្រឹក ។ មានពាណិជ្ជករមួយចំនួនតូចដែរដែលយកត្រីមកមណ្ឌលបែងចែកនៅពេលរសៀល ។

ថ្វីត្បិតការលក់ត្រីពីអ្នកនេសាទទៅពាណិជ្ជករធ្វើតាមការចរចាថ្លៃក្តី ក៏អ្នកនេសាទច្រើនតែត្រូវចាញ់ប្រៀប ដោយសារការពឹងផ្អែកលើឥណទាន និងគ្មានពត៌មានទីផ្សារគ្រប់គ្រាន់ ។ អ្នកនេសាទភាគច្រើនជំពាក់បំណុលពាណិជ្ជករ ។ អ្នកនេសាទខ្ចីពីពាណិជ្ជករ (ហើយពាណិជ្ជករខ្លួនឯងជារឿយៗខ្ចីប្រាក់ពីអ្នកបែងចែក) ដើម្បីទិញទូក និងឧបករណ៏នេសាទ ទិញប្រេងឥន្ធនៈ ឬដោះស្រាយចំណាយនៅពេលមានជំងឺធ្ងន់បណ្តាលឱ្យបាត់បង់ចំណូល និង/ឬចំណាយព្យាបាល ។ ពាណិជ្ជករមិនយកការប្រាក់ពី

[១] ច្បាប់ស្តីពីការគ្រប់គ្រងវិស័យជលផលឆ្នាំ១៩៨៧ (លេខ ៣៣ ក្រ ច) កំណត់រដូវបិទនេសាទរយៈពេល៤ខែ ដើម្បីឱ្យត្រីពង កូន និងធំលូតលាស់ ។ រដូវបិទនេសាទគឺចាប់ពីថ្ងៃទី០១ មិថុនា ដល់ ៣០ កញ្ញា នៅភាគខាងជើងទីក្រុងភ្នំពេញ និងពីថ្ងៃទី០១ កក្កដា ដល់ ៣១ តុលា នៅភាគខាងត្បូងទីក្រុងភ្នំពេញ ។ រដូវសំបូរត្រីស្ថិតក្នុងចន្លោះខែវិច្ឆិកា និងមិថុនា ទៅតាមកន្លែងខុសៗគ្នា ។

អ្នកនេសាទទេ ប៉ុន្តែទាមទារឱ្យអ្នកនេសាទលក់ត្រីចាប់បានទាំងអស់ទៅឱ្យពួកគេវិញ នៅក៏រិតថ្លៃមួយដែលគេបញ្ចុះទាប (ដែលអាចចាត់ទុកថាជា អត្រាការប្រាក់បង្កប់លើកំចី)[២] ។ អ្នកនេសាទសងបំណុលតាមការ កាត់សង/បង់ប្រាក់ជាទៀងទាត់ ឬសងសរុបនៅចុងរដូវនេសាទ ។

ការពឹងផ្អែកខាងហិរញ្ញវត្ថុរបស់អ្នកនេសាទទៅលើពាណិជ្ជករ ធ្វើឱ្យអ្នកនេសាទចាញ់ប្រៀបជាខ្លាំងក្នុងការចរចាថ្លៃ ។ អ្នកនេសាទមានលទ្ធភាពជំទាស់តិចតួចណាស់ ក្រៅពីការព្រមទទួលយកថ្លៃកំណត់ដោយពាណិជ្ជករជាម្ចាស់បំណុលរបស់ខ្លួន ។ ប៉ុន្តែនៅពេលត្រូវការប្រាក់ភ្លាមៗក្នុងរដូវនេសាទ អ្នកនេសាទលក់ត្រីម្តងម្កាលដែរទៅឱ្យពាណិជ្ជករដែលមិនមែនជាម្ចាស់បំណុលរបស់ខ្លួន ដើម្បីជៀសវាងការទូទាត់ប្រាក់កំចី ។ ដើម្បីទប់ស្កាត់អ្នកនេសាទ ក្នុងការលក់ត្រីទៅឱ្យពាណិជ្ជករផ្សេង (ដែលផ្ទុយនឹងកិច្ចព្រមព្រៀងកំចីផ្ទាល់មាត់) ជារឿយៗពាណិជ្ជករចុះទូកទៅទិញត្រីពីអ្នកនេសាទ/កូនបំណុលនៅកន្លែងរកត្រី ដោយមិនបាច់ឱ្យអ្នកនេសាទធ្វើដំណើរមកកន្លែងឡើងត្រីទេ ។

ជំហរតថ្លៃទន់ខ្សោយរបស់អ្នកនេសាទជាមួយពាណិជ្ជករ អាចកាន់តែខ្សោយថែមដោយសារកង្វះពត៌មានទីផ្សារ ។ ក្នុងការចរចាថ្លៃ អ្នកនេសាទពឹងផ្អែកលើថ្លៃត្រីពីថ្ងៃមុនដែលខ្លួនបានដឹង, ពត៌មានតាមមាត់ពីថ្លៃត្រី ទទួលបានពីអ្នកនេសាទឯទៀត, និងការស្វែងយល់ខ្លះៗពីបរិមាណត្រីចាប់បាននៅកន្លែងនេសាទ ។ តាមធម្មតាចាប់តាំងពីពេលលក់ត្រីលើកចុងក្រោយ ពួកគេគ្មានទទួលពត៌មានអ្វីពីការប្រែប្រួលថ្លៃត្រីនៅមណ្ឌលបែងចែក និងទីផ្សារលក់រាយទេ ។ ផ្ទុយទៅវិញ ពាណិជ្ជករធ្វើការទាក់ទងជាប្រចាំជាមួយអ្នកបែងចែកតាមអាយ-កូម ឬទូរស័ព្ទ ពីការប្រែប្រួលប្រចាំថ្ងៃលើថ្លៃត្រី និងពីតំរូវការ/ការផ្គត់ផ្គង់ត្រីនៅទីផ្សារ ដែលផ្តល់ប្រៀបដល់ការចរចាថ្លៃ ។ តាមធម្មតា ពាណិជ្ជករផ្តល់ថ្លៃឆាកាមួយសំរាប់ត្រីទិញចូលទាំងអស់ (ជួនកាលមិនទាំងគិតពីប្រភេទ និងទំហំត្រីខុសគ្នាផង) ។ វិធីនេះជួយសំរួលដល់ការលក់ និងកាត់បន្ថយពេលធ្វើប្រតិបត្តិការពាណិជ្ជកម្ម ហើយនេះជាកត្តាសំខាន់ សំរាប់ពាណិជ្ជករដែលត្រូវធ្វើការជាមួយអ្នកនេសាទច្រើននាក់ ។

## ២.២. ប្រតិបត្តិការពាណិជ្ជកម្មទី២ ពីពាណិជ្ជករទៅអ្នកលក់រាយតាមរយៈអ្នកបែងចែក

ភាគច្រើនបំផុតនៃត្រីលក់ចេញនៅទីផ្សារលក់រាយក្រុងភ្នំពេញ ដំបូងត្រូវឆ្លងកាត់មណ្ឌលបែងចែកមួយក្នុងចំណោមមណ្ឌលបែងចែកផលនេសាទបីកន្លែងដែលមានអាជ្ញាប័ណ្ណរបស់សាលាក្រុងភ្នំពេញគឺ មណ្ឌលបែងចែកផលនេសាទច្រាំងចំរេះ (ស្ថិតនៅចំងាយ ៩គម ពីខាងជើងក្រុងភ្នំពេញ តាមផ្លូវជាតិលេខ ៥) កំពង់ផែបែងចែកត្រីក្រុងភ្នំពេញ (ស្ថិតនៅចំងាយ ១១,៥គម ពីខាងជើងក្រុងភ្នំពេញ តាមដងទន្លេសាប) និងមណ្ឌលបែងចែកត្រីច្បារអំពៅ (ស្ថិតនៅខាងត្បូងក្រុងភ្នំពេញ តាមផ្លូវជាតិលេខ ១) ។ ភាគច្រើននៃត្រីដាក់ទឹកកកដឹកពីបឹងទន្លេសាបតាមរថយន្ត សំរាប់លក់ចេញនៅភ្នំពេញ ត្រូវបានបែងចែកតាមរយៈ ១៩តូបបែងចែកនៅច្រាំងចំរេះ (ជារបស់អ្នកបែងចែក ១៨នាក់ ក្នុងនេះអ្នកបែងចែកម្នាក់មានតូបពីរ) ។ ត្រីរស់មកពីបឹងទន្លេសាប តាមធម្មតាច្រើនតែដឹកតាមផ្លូវទឹក និងបែងចែកតាមរយៈ ២២តូបបែងចែកនៅកំពង់ផែបែងចែកត្រីក្រុងភ្នំពេញ ។ ត្រីយកមកពីភាគខាងត្បូងក្រុងភ្នំពេញសំរាប់លក់ក្នុងរាជធានី តាមធម្មតាត្រូវបានបែងចែកតាមរយៈ ១០តូប នៅមណ្ឌលបែងចែកផលនេសាទច្បារអំពៅ ។ បន្ថែមទៅលើមណ្ឌលបែងចែកមានអាជ្ញាប័ណ្ណ មានមណ្ឌលបែងចែកផលនេសាទតូចៗគ្មានអាជ្ញាប័ណ្ណជាច្រើន កំពុងដំណើរការក្រៅផ្លូវការនៅជុំវិញក្រុងភ្នំពេញ ។

---

[២] តាមទិន្នន័យប្រមូលសំរាប់ការសិក្សានេះ គេមិនអាចប៉ាន់ស្មានបានពីទំហំអត្រាការប្រាក់ដែលពាណិជ្ជករយកពីអ្នកនេសាទទេ ។ ការលំបាកមួយ គឺត្រូវរកឱ្យឃើញពីគំលាតក្នុងកំរិតថ្លៃលក់បាន (សំរាប់ត្រីមានតំលៃប្រហាក់ប្រហែលគ្នា) រវាងអ្នកនេសាទ ដែលជំពាក់បំណុល និងអ្នកនេសាទមិនជំពាក់បំណុល ។ ដោយមានអ្នកនេសាទច្រើនណាស់ជំពាក់បំណុលគេ ដូច្នេះវាពិបាកនឹងរកឃើញកំរិតថ្លៃទីផ្សារធម្មតា ដែលអ្នកនេសាទគ្មានជំពាក់បំណុលអាចលក់ត្រីបាន ។

មណ្ឌលច្រាំងចំរេះគ្រប់គ្រងលើសកម្មភាពបែងចែកត្រីភាគច្រើន, បន្ទាប់មកគឺ ផែបែងចែកត្រីរាជធានីភ្នំពេញ និងមណ្ឌលបែងចែកផលនេសាទច្បារអំពៅ (Ouch 1996)[៣] ។ ដោយមូលហេតុនេះ និងដោយសារវាជាមណ្ឌលបែងចែកចំបងគេសំរាប់ផ្លូវពាណិជ្ជកម្មបឹងទន្លេសាប-ភ្នំពេញ ដូច្នេះប្រតិបត្តិការពាណិជ្ជកម្មត្រីនៅមណ្ឌលច្រាំងចំរេះគឺជាចំណុចផ្តោតនៃការសិក្សានេះ (សូមអានពតិមាន ក្នុងប្រអប់) ។

**មណ្ឌលបែងចែកផលនេសាទច្រាំងចំរេះ**

ចាប់ពីឆ្នាំ១៩៨៤-៩៦ មណ្ឌលបែងចែកផលនេសាទផ្សារតូចក្នុងខ័ណ្ឌដូនពេញជិតគល់ស្ពានមិត្តភាពកម្ពុជាជប៉ុន គឺជាមណ្ឌលបែងចែកផលនេសាទចំបងគេដែលបំរើក្រុងភ្នំពេញ ។ មណ្ឌលនេះគ្រប់គ្រងដោយមនុស្សមួយក្រុមដែលគេហៅថា ក្រុមសាមគ្គី និងដែលតាមរយៈនេះ រដ្ឋផ្តល់សិទ្ធិឱ្យអ្នកបែងចែកត្រីធ្វើប្រតិបត្តិការនៅក្នុងមណ្ឌល និងប្រមូលប្រាក់កំរៃ ៣% លើគ្រប់ចំនួលលក់ ។ ជាចំណែកមួយនៃកិច្ចប្រឹងប្រែងរបស់សាលាក្រុង ដើម្បីកាត់បន្ថយការស្ទះចរាចរក្នុងក្រុង មណ្ឌលបែងចែកផលនេសាទផ្សារតូចត្រូវបានដូរទីតាំងទៅតំបន់មួយចំងាយ ៩គ.ម ពីខាងជើងក្រុងភ្នំពេញតាមបណ្តោយផ្លូវជាតិលេខ ៥ និងប្តូរឈ្មោះទៅជាមណ្ឌលបែងចែកផលនេសាទច្រាំងចំរេះ ។ អ្នកបែងចែកត្រីដែលមានតូបនៅផ្សារតូច បានទទួលការអនុញ្ញាតឱ្យផ្ទេរសិទ្ធិកាន់កាប់តូប ទៅកាន់កាប់តូបនៅច្រាំងចំរេះដោយគ្មានបង់ប្រាក់ ។ សព្វថ្ងៃ អ្នកបែងចែកត្រីភាគច្រើននៅច្រាំងចំរេះគឺជាអ្នកបែងចែកត្រីនៅផ្សារតូចពីមុន ។

វិនិយោគិនឯកជន បានផ្តល់ហិរញ្ញប្បទានដើម្បីសាងសង់មណ្ឌល និងតូបទាំង ១៩ តាមកិច្ចព្រមព្រៀងមួយជាមួយសាលាក្រុងភ្នំពេញ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ យោងតាមកិច្ចព្រមព្រៀងគំរោង វិនិយោគនេះមានរយៈ៨ឆ្នាំ ចាប់ពីឆ្នាំ១៩៩៥-២០០៣ ហើយអាចបន្តទៀតបានតាមកិច្ចចរចារវាងវិនិយោគិន និងរដ្ឋាភិបាល ។ បន្ថែមទៅលើចំណាយសាងសង់មណ្ឌលបែងចែកចំណាយដំណើរការ និងការថែទាំ វិនិយោគិន ត្រូវបង់ប្រាក់ប្រចាំឆ្នាំចំនួន ២.១៥០.០០០រៀល (ត្រូវជា ៥៤៨ដុល្លារ) សំរាប់ថ្លៃឈ្នួលដីរដ្ឋដែលសង់មណ្ឌលលើនោះ បង់វិភាគទានផ្សេងៗសំរាប់គំរោងអភិវឌ្ឍន៍ផ្សេងៗរបស់សាលាក្រុង (ឧ. ជួសជុលផ្លូវ) និងបង់ពន្ធផ្សេងៗទៀតជូនរដ្ឋ ។ ចំពោះការរកចំណូលវិញ វិនិយោគិនមានសិទ្ធិយកប្រាក់កំរៃ ៣% លើចំណូលលក់បានទាំងអស់នៅមណ្ឌលបែងចែកផលនេសាទ ។ អ្នកបែងចែកត្រីណាដែលចង់ផ្ទេរ សិទ្ធិកាន់កាប់តូបទៅឱ្យម្ចាស់ថ្មីម្នាក់ទៀត ត្រូវចរចាជាតាមរយៈម្ចាស់មណ្ឌលបែងចែក និងរដ្ឋអំណាចជាប់ពាក់ព័ន្ធ ។ យោងតាមមន្ត្រីមកពីមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានីភ្នំពេញ ម្ចាស់មណ្ឌលបែងចែក និងសាលាក្រុងភ្នំពេញ បានព្រមព្រៀងគ្នាលើកិច្ចសន្យាថ្មីមួយចាប់ពីឆ្នាំ២០០៤ ។

---

[៣] Ouch (1996) បានពិនិត្យលើស្ថិតិបែងចែកត្រីក្នុងរយៈ៨ខែ ដើមឆ្នាំ១៩៩៦ ហើយរកឃើញថា ក្នុងបរិមាណត្រីបែងចែកតាមរយៈមណ្ឌលទាំងបីមាន ៦៤% បែងចែកតាមមណ្ឌលបែងចែកផលនេសាទផ្សារតូច (ក្រោយមកដូរឈ្មោះជា មណ្ឌលបែងចែក ផលនេសាទច្រាំងចំរេះ) ២៤% តាមផែបែងចែកត្រីរាជធានីភ្នំពេញ និង ១២% តាមមណ្ឌលបែងចែកផលនេសាទច្បារអំពៅ ។ ថ្វីបើ ការដូរកន្លែង/ដូរឈ្មោះមណ្ឌលច្រាំងចំរេះទៅក្រៅរាជធានីភ្នំពេញ ប្រហែលធ្វើឱ្យធ្លាក់ចុះសកម្មភាពបែងចែកត្រីខ្លះក្តី ប៉ុន្តែ អ្នកបែងចែកនានាបានឆ្លើយសំភាសន៍ប្រាប់ថា ច្រាំងចំរេះនៅតែជាមណ្ឌលបែងចែកផលនេសាទធំជាងគេដដែល ។



កម្មករកំពុងផ្ទុកត្រីលើរថយន្តនៅកន្លែងឡើងត្រីកំពង់លួង ខេត្តពោធិសាត់

ប៉ុន្តែ បទសំភាសន៍នានាជាមួយអ្នកបែងចែកនៅមណ្ឌលច្រាំងចំរេះ និងច្បារអំពៅ បានផ្តល់គំនិតថា មណ្ឌលបែងចែកទាំងបី មានបែបបទដំណើរការប្រហាក់ប្រហែលគ្នា ។

ពាណិជ្ជករដឹកត្រីពីកន្លែងឡើងត្រីនៅកំពង់លួង និងកំពង់ឆ្នាំង មកច្រាំងចំរេះពេញមួយឆ្នាំ ។ នៅមណ្ឌលបែងចែក គេរើត្រីដាក់ក្នុងតូបរបស់អ្នកបែងចែកណាមួយ ហើយលក់ទៅឱ្យអ្នកលក់រាយ ។ ជាទូទៅ អ្នកបែងចែកម្នាក់ៗរកស៊ីជាមួយពាណិជ្ជករ ១៥-២៥នាក់ ដោយផ្តល់ហិរញ្ញប្បទានសំរាប់សកម្មភាពប្រមូលទិញត្រី, ផ្តល់សេវា ដូចជា កំលាំងពលកម្មរើត្រីពីរថយន្ត និងក្នុងករណីខ្លះជួយពាណិជ្ជករធ្វើការចរចាថ្លៃជាមួយអ្នកលក់រាយ ។ តួនាទីសំខាន់បំផុតរបស់អ្នកបែងចែក គឺការផ្តល់ដើមទុនដ៏ចាំបាច់ដល់ពាណិជ្ជករសំរាប់ការប្រមូលទិញត្រី (ហើយពាណិជ្ជករឱ្យអ្នកនេសាទខ្ចីទុនខ្លះជាបន្ត) ។ ខ្សែរយៈផ្តល់ហិរញ្ញប្បទានប្រហាក់ប្រហែលគ្នានេះ ក៏ឃើញមាននៅក្នុងម៉ាឃីទីងនៃត្រីនាំចេញដែរ ដោយអ្នកនាំចេញផ្តល់ហិរញ្ញប្បទានឱ្យពាណិជ្ជករ ហើយពាណិជ្ជករឱ្យខ្ចីទុនខ្លះជាបន្តដល់អ្នកនេសាទ (Yim and McKenney 2003) ។

គ្មានអ្វីគួរឱ្យភ្ញាក់ផ្អើលទេដែលអ្នកបែងចែកមិនសូវចង់ពិភាក្សាពីទំហំទឹកប្រាក់កំចីរបស់គេ ប៉ុន្តែ ពិនិត្យតាមចំនួនពាណិជ្ជករ និងបរិមាណត្រីត្រូវទិញសំរាប់ការដឹកចេញមួយលើកៗ ហិរញ្ញប្បទានសំរាប់ពាណិជ្ជកម្មត្រីដែលផ្តល់ដោយអ្នកបែងចែកធុនមធ្យមម្នាក់នៅពេលណាក៏ដោយ ក៏មានប្រហែលពី ១០.០០០-៥០.០០០ដុល្លារដែរ ។ អ្នកបែងចែកផ្តល់ហិរញ្ញប្បទាននេះដោយប្រើមូលធនរបស់ខ្លួនផ្ទាល់ ។ ម្តងម្កាលពួកគេខ្ចីទុនរយៈពេលខ្លីពីស្ថាប័ន ឬអ្នករកស៊ីចងការប្រាក់ ដើម្បីបំពេញតំរូវការឥណទានរយៈពេលខ្លីតាមអត្រាការប្រាក់ប្រចាំខែពី ៣-៥% ។

ក្នុងករណីភាគច្រើន អ្នកបែងចែកស្គាល់ពាណិជ្ជករដែលរកស៊ីជាមួយខ្លួនជាយូរមកហើយ ដូច្នេះមានការទុកចិត្តគ្នាច្រើន ហើយការផ្តល់ហិរញ្ញប្បទានក៏មានហានិភ័យតិចដែរ ។ ជាការតបស្នងដល់ការផ្តល់ហិរញ្ញប្បទាន និងសេវាកម្មពីអ្នកបែងចែក ពាណិជ្ជករយល់ព្រមលក់ត្រីទាំងអស់ទៅឱ្យអ្នកបែងចែក ដោយមានការព្រមព្រៀងផ្ទាល់មាត់ថា ពាណិជ្ជករនឹងបង់ឱ្យអ្នកបែងចែកនូវ "កំរៃជើងសារ" ពេលលក់ទៅឱ្យអ្នកលក់រាយម្តងៗ ។ ប្រាក់កំរៃនេះគឺយក ១០០រៀល/គ.ក ចំពោះត្រីថ្លៃទាបជាង ២.០០០រៀល/គ.ក (០,៥០ដុល្លារ) និង ២០០រៀល/គ.ក ចំពោះត្រីថ្លៃខ្ពស់ជាង ២.០០០រៀល/គក ។ ប៉ុន្តែ មានអ្នកបែងចែកខ្លះកំណត់បន្ទាត់ថ្លៃទាបជាង ២.០០០រៀល/គ.ក និងមានខ្លះទៀតកំណត់ខ្ពស់ជាង ២.០០០រៀល/គ.ក ។



មណ្ឌលបែងចែកផលនេសាទច្រាំងចំរេះ

បន្ថែមទៅលើការបង់ប្រាក់កំរៃខាងលើឱ្យអ្នកបែងចែក ពាណិជ្ជករត្រូវបង់ប្រាក់ឱ្យម្ចាស់មណ្ឌលបែងចែកចំនួន ៣% ទៀតលើចំណូលលក់បានទាំងអស់ ។ បុគ្គលិកមណ្ឌលបែងចែកពិនិត្យតានដានការលក់និមួយៗ និងកត់ត្រាចំណូល និងថ្លៃលក់ ប៉ុន្តែមិនប្រមូលប្រាក់កំរៃ ៣% នៅពេលនោះភ្លាមទេ ។ អ្នកបែងចែកត្រូវប្រមូលប្រាក់កំរៃ ៣% នេះពីពាណិជ្ជករ និងទូទាត់បង់ឱ្យបុគ្គលិកមណ្ឌលបែងចែកនៅពេលចាប់ផ្តើមដំណើរការលក់ដូរនាព្រឹកបន្ទាប់ ។

សរុបមក ពាណិជ្ជករត្រូវបង់ប្រាក់ប្រហែល ១០% នៃចំណូលលក់ទាំងអស់ទៅឱ្យអ្នកបែងចែក និងម្ចាស់ មណ្ឌលបែងចែក គឺប្រហែល ៦-៨% បង់ឱ្យអ្នកបែងចែកចំពោះការផ្តល់ហិរញ្ញប្បទាននិងសេវា និង ៣% ដល់ម្ចាស់មណ្ឌលបែងចែក ។ ដើម្បីបង្ហាញជាតួលេខជាក់ស្តែងមួយ អាចលើកយកករណីពាណិជ្ជករម្នាក់មានត្រី ២តោន ក្នុងនេះ ១តោនលក់ឱ្យអ្នកលក់រាយ ថ្លៃ ១.៥០០រៀល/គ.ក (០,៣៨ដុល្លារ) និង ១តោនទៀតលក់ ២.៥០០រៀល (០,៦៣ដុលារ) ។ លើត្រី ១តោនដំបូង ពាណិជ្ជករទទួលបាន ៣៨០ដុល្លារ ប៉ុន្តែត្រូវបង់ ២៥ដុល្លារឱ្យអ្នកបែងចែក និង ១១ដុល្លារឱ្យម្ចាស់មណ្ឌលបែងចែក, គឺសរុបមកត្រូវបង់ប្រាក់កំរៃអស់ជិតដល់ ១០% នៃចំណូលពីការលក់ ។ ចំពោះត្រី ១តោនចុងក្រោយ ពាណិជ្ជករទទួលបាន ៦៣២ដុល្លារ ប៉ុន្តែត្រូវបង់ ៥១ដុល្លារឱ្យអ្នកបែងចែក និង ១៩ដុល្លារឱ្យម្ចាស់មណ្ឌលបែងចែក គឺសរុបមកត្រូវបង់ប្រាក់កំរៃអស់ប្រហែល ១១% នៃចំណូលពីការលក់ ។

ត្រីបានលក់ទៅឱ្យអ្នកលក់រាយដោយយកប្រាក់ភ្លាម ឬឱ្យជំពាក់ទៅតាមទំនាក់ទំនងរវាងអ្នកលក់រាយ និង ពាណិជ្ជករ/អ្នកបែងចែក ។ អ្នកលក់រាយដែលមានទំនាក់ទំនងយូរអង្វែងជាមួយពាណិជ្ជករ/អ្នកបែងចែក អាចសុំជំពាក់បាន ១ថ្ងៃ ដូច្នេះអាចយកត្រីទៅលក់នៅទីផ្សារ ហើយទូទាត់ឱ្យអ្នកបែងចែកវិញនៅព្រឹកបន្ទាប់ ។ ក្នុងការចាត់ចែងបែបនេះ អ្នកបែងចែកទូទាត់ប្រាក់ឱ្យពាណិជ្ជករភ្លាមៗដើម្បីគេអាចវិលទៅកន្លែងឡើងត្រីវិញ និងធ្វើការទិញដូរត្រីបន្ត ។ អ្នកលក់រាយដែលគ្មានទំនាក់ទំនងយូរអង្វែងជាមួយពាណិជ្ជករ/អ្នកបែងចែក ត្រូវទូទាត់សងប្រាក់ ដោយផ្ទាល់ទៅឱ្យពាណិជ្ជករ ។

## ២.៣. ប្រតិបត្តិការពាណិជ្ជកម្មទី៣ ពីអ្នកលក់រាយទៅអតិថិជន

ចេញពីមណ្ឌលបែងចែកផលនេសាទនៅក្រៅក្រុងភ្នំពេញទៅ ត្រីត្រូវបានដាក់លក់នៅតាមផ្សារសំខាន់ៗក្នុងក្រុង ផ្សារទំនើប ភោជនីយដ្ឋាន អ្នកកែច្នៃ និងកន្លែងលក់អាហារតាមដងផ្លូវ និងជុំវិញក្រុងភ្នំពេញ ។ ត្រីខ្លះបានបែងចែកទៅបណ្តាខេត្តជិតៗ ដូចជា ខេត្តកំពង់ស្ពឺដែលពុំមានកន្លែងធ្វើនេសាទច្រើន ។ ការសិក្សានេះផ្តោតលើការលក់រាយត្រីនៅផ្សារធំៗពីរនៅភ្នំពេញ គឺ ផ្សារអូរឬស្សី និងផ្សារធំថ្មី ។ សឹងតែពេញមួយឆ្នាំៗ អ្នកលក់រាយនៅផ្សារពីរនេះ លក់ត្រីប្រហែល ២-៥តោន/ថ្ងៃនូវត្រីរក្សាក្នុងទឹកកកដល់អតិថិជននៅទីក្រុង ។ ប៉ុន្តែបរិមាណនេះ អាចកើនខ្ពស់ច្រើននៅរដូវសំបូរត្រី ។

ការសិក្សានេះរកឃើញថា មានអ្នកលក់រាយ ៣៥នាក់នៅផ្សារធំថ្មី និង ២៨នាក់នៅផ្សារអូរឬស្សី ។ អ្នកលក់រាយទាំងអស់ជាស្ត្រី ប៉ុន្តែអ្នកខ្លះគេមានបុរសជួយធ្វើស្រកាត្រីឱ្យ ។ អ្នកលក់រាយប្រាប់ថា ធ្វើការលក់ត្រីពេញមួយឆ្នាំៗ ប៉ុន្តែភាគច្រើនជួលតូបនៅផ្សារប្រចាំខែ និងមានខ្លះទៀតជួលប្រចាំថ្ងៃ ។ អ្នកលក់រាយជាទូទៅ មានធុង ជ្រុញ កំបិត និងជញ្ជីង ។ ពួកគេទៅមណ្ឌលបែងចែកត្រីច្រាំងចំរេះ ដើម្បីទិញត្រីនៅម៉ោង ៣-៤ទៀបភ្លឺ ដើម្បីរៀបចំត្រីសំរាប់លក់នៅម៉ោង ៦-៧ព្រឹក ។ អ្នកលក់រាយភាគច្រើនដំនើរការក៏រិតតូចដោយទិញ ៣០-៧០គ.ក/ថ្ងៃនូវត្រីចំរុះ (តិចជាង ៥ប្រភេទ) ប៉ុន្តែអ្នកលក់រាយខ្លះគេផ្តោតលើតែត្រីមួយប្រភេទជាក់លាក់ ។ អ្នកលក់ជាច្រើនក៏ទៅទិញត្រីនៅម៉ោង ២-៣រសៀលដែរសំរាប់លក់នៅពេលរសៀល និងល្ងាច ។

អ្នកលក់រាយប្រាប់ថា ចំណូលពីការលក់ត្រីប្រែប្រួលយ៉ាងខ្លាំង ។ នៅថ្ងៃទិញបានត្រីពីមណ្ឌលបែងចែក គេតែងលក់វាអស់នៅមុនពេលបាយថ្ងៃត្រង់ ប៉ុន្តែជួនកាលក៏នៅសល់ត្រីជាងពាក់កណ្តាលរហូតដល់ល្ងាចដែរ ។ ដោយសារភាពមិនប្រាកដប្រជានេះ និងបញ្ហាចោទក្នុងការរក្សាត្រីឱ្យនៅស្រស់ (សូមអានចំណុច៣.១) អ្នកលក់រាយ តាមធម្មតាគេយកចំណេញប្រហែល ៣០-១០០% ពីលើថ្លៃត្រីទិញចូលអំពីមណ្ឌលបែងចែក ។ កំរិតថ្លៃនេះគេកំណត់ សំរាប់អ្នកទិញពេលព្រលឹម ប៉ុន្តែអាចថយចុះច្រើនណាស់តាមពេលវេលាកន្លងទៅក្នុងព្រឹកនោះ យោងតាមដំណើរការលក់ដូរ ។ ត្រីលក់មិនដាច់នៅចុងថ្ងៃជារឿយៗ គេកែច្នៃសំរាប់លក់ទៅថ្ងៃក្រោយ ឬលក់ចុះថ្លៃឱ្យភោជនីយដ្ឋានតូចៗ និងកន្លែងលក់អាហារតាមដងផ្លូវ ដែលតាមធម្មតា គឺជាថ្លៃលក់ខាតចំពោះអ្នកលក់រាយ ។ ទោះបីអ្នកលក់រាយ មានសំណាងល្អអាចលក់ត្រីអស់នៅមុនពេលបាយថ្ងៃត្រង់ក្តី ក៏ចំណូលរបស់ពួកគេមិនបានច្រើនណាស់ណាទេ (សូមអានពត៌មានក្នុងប្រអប់ខាងក្រោម) ។

ការលក់ត្រីរាយ

### ថ្ងៃល្អមួយនៅផ្សារធំថ្មី

លោកស្រី សុខ* ទិញត្រីបីប្រភេទ ទំងន់ ៣៤,៥គ.កគឺ ត្រីសណ្តាយ (Wallago attu), ត្រីឆ្លាំង (Mystus nemurus) និង ត្រីកែស (Miconema spp.) ពីមណ្ឌលបែងចែកផលនេសាទច្រាំងចំរេះ អស់ថ្លៃសរុប ២២០.៥០០រៀល (៥៥ដុល្លារ) ។ ធៀបនឹងកំរិតថ្លៃនៅមណ្ឌលបែងចែក គាត់បានបន្ថែមថ្លៃសំរាប់លក់រាយ ៤០-៥០%ទៀត ចំពោះត្រីមួយប្រភេទៗ ។ គាត់ចាប់ផ្តើមលក់នៅម៉ោង ៧ព្រឹក ហើយលក់អស់ប្រហែល ២ភាគបីនៃត្រីទិញចូល (២៣,៥គ.ក) នៅម៉ោង ៩ព្រឹក នៅកំរិតថ្លៃបានគិតបន្ថែមពីដើមទី ។ នៅម៉ោង ៩-១០ព្រឹក លោកស្រី សុខ លក់ចុះថ្លៃប្រហែល ១០-១៥% ហើយលក់អស់ ៨គ.កថែមទៀត គឺនៅសល់តែ ៣គ.ក សំរាប់លក់បន្ត ។ នៅចុងបញ្ចប់ ដោយលក់ចុះថ្លៃស្មើឬទាបជាងថ្លៃទិញត្រីចូលពីមណ្ឌលបែងចែក គាត់អាចលក់ត្រីអស់នៅម៉ោង ១១ ព្រឹក ។

លោកស្រីសុខ ចាត់ទុកថ្ងៃនេះជាថ្ងៃល្អមួយក្នុងរបរលក់ត្រីរបស់គាត់ ។ ចំណូលដុលរបស់គាត់គឺ ២៨.៧៥០រៀល (ប្រហែល ៧ដុល្លារ) ។ គាត់រាយការណ៍ថា ចំណុលដុលរបស់គាត់មានពី ១០.០០០រៀល ទៅ ៥០.០០០រៀល (២,៥-១២,៥ ដុល្លារ) ប៉ុន្តែជាទូទៅពី ២០.០០០-៣០.០០០រៀល (៤-៧,៥ដុល្លារ) ។ បន្ទុកចំណាយក្នុងរបរលក់ត្រីរបស់គាត់ គឺប្រហែល ៦.០០០រៀល/ថ្ងៃ (១,៥ដុល្លារ) ។

* ឈ្មោះអ្នកលក់រាយបានប្តូរចេញ ដើម្បីគោរពតាមបំណងរបស់សាមីខ្លួនដែលមិនចង់ឱ្យគេស្គាល់ ។

# ជំពូក ៣

# ចំណាយម៉ាឃីទីងត្រីសំខាន់ៗ និងឧបសគ្គ

មានបញ្ហាប្រឈមជាច្រើនចំពោះម៉ាឃីទីងត្រីពីបឹងទន្លេសាបទៅភ្នំពេញ ទាក់ទិននឹងការទិញដូរ ការលើកដាក់រៀបចំ ការស្តុក ការប្រមូលទុកឱ្យបានគ្រប់ ការដឹកជញ្ជូន និងសកម្មភាពលក់ ។ ការស្វែងយល់ពីហានិភ័យ និងឧបសគ្គខាងម៉ាឃីទីងទាំងនេះគឺមានសារៈសំខាន់ ពីព្រោះវាជះឥទ្ធិពលអវិជ្ជមានដល់ចំណូលមិនត្រឹមតែរបស់ពាណិជ្ជករនិងអ្នកលក់រាយប៉ុណ្ណោះទេ ប៉ុន្តែទាំងរបស់អ្នកនេសាទ និងអ្នកមានរបរទាក់ទិននឹងវិស័យនេសាទទៀតផង ។ នេះជាចំណុចសំខាន់បំផុត ។ នៅពេលចំណាយម៉ាឃីទីងកើនឡើង ពាណិជ្ជករនិងអ្នកលក់រាយត្រូវផ្ទេរវាទៅឱ្យអ្នកនេសាទ ដោយបន្ទាបថ្លៃត្រីរបស់ពួកគេ ហើយផ្ទេរចំណាយនេះទៅអ្នកប្រើប្រាស់ ដោយបង្កើនថ្លៃលក់រាយនៅទីផ្សារ ។ ផ្ទុយទៅវិញនៅពេលម៉ាឃីទីងកើនប្រសិទ្ធិភាព និងថយបន្ទុកចំណាយ អត្ថប្រយោជន៍ទាំងនេះមួយចំណែក នឹងបានទៅដល់អ្នកនេសាទ និងអ្នកប្រើប្រាស់ ។

ដើម្បីផ្តល់គំនិតខ្លះពីចំណូលម៉ាឃីទីងបច្ចុប្បន្ន (ស្មើនឹងថ្លៃបង់ដោយអ្នកប្រើប្រាស់ ដកនឹងថ្លៃបង់ឱ្យអ្នកនេសាទ) លើពាណិជ្ជកម្មត្រីពីបឹងទន្លេសាបទៅភ្នំពេញ, បានប្រមូលទិន្នន័យថ្លៃសំរាប់ម៉ាឃីទីងត្រីមានលក់ដូរជាទូទៅ ៣ប្រភេទគឺ ត្រីឆ្លាំង (Mystus nemurus), ត្រីឆ្កោក (Cyclocheilichthys spp.), និងត្រីឆ្តោរ (Channa micropeltes) ។ ទិន្នន័យទាំងនេះបង្ហាញពី "រូបភាព" ក្នុងមួយថ្ងៃនៃថ្លៃមធ្យមរបស់ត្រី៣ប្រភេទនេះលើការលក់ពីអ្នកនេសាទទៅពាណិជ្ជករ ពីពាណិជ្ជករទៅអ្នកលក់រាយ និងពីអ្នកលក់រាយទៅអ្នកប្រើប្រាស់ (តារាង ៣.១) ។ ជាមួយនឹងការរំពឹងទុកថា ថ្លៃនៅបឹងទន្លេសាប និងនៅទីផ្សារលក់រាយភ្នំពេញ វាឡើងចុះតាមគ្នារហូតពេញមួយឆ្នាំៗ ទៅតាមការប្រែប្រួលបរិមាណផ្គត់ផ្គង់និងតំរូវការត្រី ប៉ុន្តែគេក៏រំពឹងដែរថា ចំណូលម៉ាឃីទីងប្រែប្រួលតិចជាង ពីព្រោះវាជាប់ទាក់ទិនយ៉ាងជិតស្និទ្ធនឹងចំនាយម៉ាឃីទីង (ដឹកជញ្ជូន ទឹកកក ហិរញ្ញប្បទាន ប្រាក់កំរៃ និងការខូចខាត) ដែលមានស្ថិរភាពជាងក្នុងមួយឆ្នាំៗ ។ ដូច្នេះ ការវាយតំលៃពីចំណូលម៉ាឃីទីងតែក្នុងមួយថ្ងៃ ក៏អាចផ្តល់ពតិមានដ៏មានប្រយោជន៍ពីកំរិតចំណូលនេះក្នុងពេញមួយឆ្នាំដែរ (គិតជាភាគរយ)[៤] ។

ចំណូលម៉ាឃីទីងសំរាប់ត្រីបីប្រភេទដែលបានសិក្សា គឺប្រហែល ៦៥-៧៥% ។ ថ្លៃត្រីផ្តល់ឱ្យអ្នកនេសាទ តំណាងឱ្យ ២៥-៣៥% នៃថ្លៃលក់រាយប៉ុណ្ណោះ ។ ប៉ុន្តែក្នុងការបកស្រាយពតិមាននេះ មានចំនុចមួយចំនួនត្រូវលើកឡើង ។ ទីមួយ ប្រសិទ្ធិភាពម៉ាឃីទីងត្រីបង្ហាញដោយចំនូលនេះ គឺពិបាកប្រៀបធៀបជាមួយប្រទេសផ្សេងទៀត ពីព្រោះកាលៈទេសៈពាណិជ្ជកម្មអាចខុសគ្នាខ្លាំង (ឧ. ចំងាយទីផ្សារ ប្រភេទត្រី...) ។ ឧទាហរណ៍ ការសិក្សាពីម៉ាឃីទីងត្រីនៅប្រទេសបង់ក្លាដេស បង្ហាញពីចំណូលម៉ាឃីទីងទាបជាងកម្ពុជា (៥0%) ប៉ុន្តែនេះតួលេខសំរាប់ពាណិជ្ជកម្មត្រីទឹកប្រៃ (Hilsha) ពីឆ្នេរសមុទ្រទៅទីផ្សារនៅទីក្រុងដ្ហាកា ដែលមានប្រតិបត្តិការពាណិជ្ជកម្ម និងបញ្ហាប្រឈមខុសគ្នាជាច្រើន (Kleih *et al.* 2003) ។ ទីពីរ ដោយកាលពីមុនមិនធ្លាប់មានធ្វើការសិក្សាពីចំណូលម៉ាឃីទីងត្រី តាមរបៀបនេះនៅកម្ពុជាសំរាប់យកមកប្រៀបធៀបគ្នា ដូច្នេះគេមិនអាចវាយតំលៃបានទេថាតើប្រសិទ្ធិភាពម៉ាឃីទីងបានកែលំអឡើងឬយ៉ាងណា ។ ប៉ុន្តែការសិក្សានេះបានផ្តល់ជាកំរិតគោលដ៏សាមញ្ញមួយ

[៤] ពិតហើយ ការស្រាវជ្រាវបន្ថែមពីចំនូលម៉ាឃីទីងនៅពេលផ្សេង លើត្រីប្រភេទផ្សេង និងតាមផ្លូវពាណិជ្ជកម្មផ្សេងទៀត អាចផ្តល់តួលេខប៉ាន់ស្មានកាន់តែច្បាស់ពីចំនូលនេះ ប៉ុន្តែគេមិនអាចធ្វើដូច្នេះបានទេក្នុងកំរិតធនធានដែលមានសំរាប់ការសិក្សានេះ ។

សំរាប់ការប្រៀបធៀបទៅអនាគត ។ ទីបី មុនពេលសន្និតថា ពាណិជ្ជករ និងអ្នកលក់រាយរកចំណូលបានច្រើន ដោយសារការបន្ថែមថ្លៃលក់ និងចំណូលម៉ាឃីទីង គេគួរពិចារណាពីហានិភ័យ និងបន្ទុកចំណាយរបស់អ្នកទាំងនេះផង (តារាង ៣.២ និង ផ្នែក ៣.១-៣.៥ ខាងក្រោម) ។ ម្យ៉ាងទៀត អ្នកលក់រាយលក់ត្រីក្នុងបរិមាណតិច (៣០-៧០គ.ក) ដូច្នេះទោះបីគេយកអត្រាចំណេញខ្ពស់លើការលក់ត្រីក្តី ក៏មិនបានចំណេញច្រើនណាស់ណាដែរ ។

តារាង៣.១. ចំនាយម៉ាឃីទីងត្រីបីប្រភេទ ពីកំពង់លួង ទៅផ្សារអូរឬស្សី និងផ្សារធំថ្មី នៅភ្នំពេញ (ធ្នូ ២០០២)

| | ត្រីឆ្លាំង | | ត្រីឆ្តោក | | ត្រីឆ្តោរ | |
|---|---|---|---|---|---|---|
| ថ្លៃលក់ចេញមធ្យម[ក] | ថ្លៃ (R/kg) | % ថ្លៃលក់រាយ | ថ្លៃ (R/kg) | % ថ្លៃលក់រាយ | ថ្លៃ (R/kg) | % ថ្លៃលក់រាយ |
| ពីអ្នកនេសាទទៅពាណិជ្ជករ | 1,000 | 24% | 1,500 | 34% | 1,700 | 35% |
| ពីពាណិជ្ជករទៅអ្នកលក់រាយ តាមរយៈអ្នកបែងចែក | 2,200 | 52% | 2,450 | 56% | 3,586 | 74% |
| ពីអ្នកលក់រាយទៅអ្នកប្រើប្រាស់ | 4,239 | 100% | 4,396 | 100% | 4,867 | 100% |
| ចំណូលម៉ាឃីទីង | 3,239 | 76% | 2,896 | 66% | 3,167 | 65% |

[ក] ទិន្នន័យថ្លៃប្រមូលបានពី បទសំភាសន៍ជាមួយពាណិជ្ជករ និងអ្នកនេសាទនៅកំពង់លួង, ការសង្កេតមើលការលក់ដូរនៅមណ្ឌលបែងចែកត្រីនៅច្រាំងចំរេះ និងបទសំភាសន៍ជាមួយអ្នកលក់រាយ និងការសង្កេតមើលការលក់ដូរនៅផ្សារអូរឬស្សី និងផ្សារធំថ្មី, នៅខែធ្នូ ២០០២ ។ ដោយសារថ្លៃលក់រាយធ្លាក់ចុះជាបន្តបន្ទាប់ក្នុងរយៈមួយព្រឹក, ក៏រិតថ្លៃលក់រាយចុះក្នុងតារាងនេះ គឺជាមធ្យមភាគសមតានៃតួលេខថ្លៃលក់រាយដែលប្រមូល បានក្នុងរយៈពេលនោះ ។

តារាង៣.២. ចំណាយមធ្យមលើការលក់ត្រីពីបឹងទន្លេសាបទៅដល់ទីផ្សារលក់រាយនៅភ្នំពេញ (ពាណិជ្ជករ និងអ្នកលក់រាយ)

| អ្នកលក់ | ចំណាយម៉ាឃីទីងមធ្យម | | | | | |
|---|---|---|---|---|---|---|
| ពាណិជ្ជករ | រៀល/គ.ក | | (ដុល្លារ/តោន)[ខ] | | % សរុប | |
| ចំណាយមូលធន និងប្រតិបត្តិការ | 531 | | 134.4 | | 50.1% | |
| ដឹកជញ្ជូន | 253 | - | 64.1 | - | 23.9% | - |
| ទឹកកក | 221 | - | 55.9 | - | 20.9% | - |
| កំលាំងពលកម្ម | 41 | - | 10.4 | - | 3.9% | - |
| សំភារៈ និងបរិក្ខារ[ក] | 16 | - | 4.1 | - | 1.5% | - |
| ការខូចខាត និងស្រកទំងន់ | 218 | | 55.2 | | 20.6% | |
| "កំរៃជើងសារ" ដល់អ្នកបែងចែក (ចំណាយហិរញ្ញប្បទាន និងសេវា) | 186 | | 47.1 | | 17.6% | |
| ប្រាក់កំរៃបង់ឱ្យម្ចាស់មណ្ឌល | 88 | | 22.3 | | 8.3% | |
| ប្រាក់កំរៃបង់ឱ្យកន្លែងកុងត្រូល និងផ្លូវថ្នល់ | 35 | | 8.9 | | 3.3% | |
| សរុបចំណាយ-ពាណិជ្ជករ | 1,059 | | 268.1 | | 100.0% | |
| អ្នកលក់រាយ | រៀល/គ.ក | | (ដុល្លារ/តោន) | | | |
| ចំណាយមូលធន និងប្រតិបត្តិការ | 149 | | 37.8 | | 95.2% | |
| ប្រាក់កំរៃ (ភាស៊ី និងអនាម័យ) | 7 | | 1.9 | | 4.8% | |
| សរុបចំណាយ-អ្នកលក់រាយ | 157 | | 39.7 | | 100.0% | |
| **សរុបចំណាយម៉ាឃីទីង** | **1,216** | | **307.8** | | **100.0%** | |

[ក] ចំណាយបន្ថែម ២៥៖/គ.ក (ឬ ៦,២ដុល្លារ/តោន ចេញដោយអ្នកបែងចែកសំរាប់ កញ្ជេ កន្ទេល បាវ ខ្សែ អាហារ និង ធុង ។

[ខ] ៣.៩៥០រៀល = ១ដុល្លារ

ម៉ាឃីទីងត្រីត្រូវប៉ះពាល់ដោយបន្ទុកចំណាយ និងឧបសគ្គជាច្រើន ដូចជាការខូចត្រី និងការស្រកទំងន់, ការត្រួតពិនិត្យការបែងចែក, ចំណាយដឹកជញ្ជូន និងទឹកកក, ចំណាយហិរញ្ញប្បទាន, និងប្រាក់កំរៃបង់តាមផ្លូវជាដើម ។ ដូចបង្ហាញក្នុងតារាង ៣.២ បន្ទុកចំណាយមធ្យមគឺប្រហែល ២៦៨ដុល្លារ/តោន ចំពោះត្រីលក់ចេញពីបឹងទន្លេសាប រហូតមកដល់មណ្ឌលបែងចែកផលនេសាទច្រាំងចំរេះ ។ ចាប់ពីមណ្ឌលបែងចែករហូតដល់អ្នកប្រើប្រាស់ បន្ទុកចំនាយលើការលក់ត្រីមានប្រហែល៤0ដុល្លារ/តោន ។ ចំពោះពាណិជ្ជករ ចំណាយប្រតិបត្តិការ និងចំណាយមូលធន តំណាងឱ្យប្រហែលពាក់កណ្តាលនៃចំណាយសរុបរបស់ពួកគេ, បន្ទាប់មកគឺមានការខូចខាត និងស្រកទំងន់ ចំនាយហិរញ្ញប្បទាន ប្រាក់កំរៃឱ្យមណ្ឌលបែងចែក និងការប្រាក់កំរៃផ្សេងៗ ។ ចំណាយរបស់អ្នកលក់រាយគឺមាន ការដឹកជញ្ជូនត្រីពីមណ្ឌលបែងចែកទៅទីផ្សារ ថ្លៃជួលតូប ថ្លៃទិញសំភារៈថ្មម្តងម្កាល និងការបង់ប្រាក់កំរៃតូចតាចខ្លះៗ ប៉ុន្តែចំណាយអ្វីផ្សេងទៀតមានតិចតួចទេ ។ ចំណាយម៉ាឃីទីងត្រី និងឧបសគ្គសំខាន់ៗ នឹងមានពិភាក្សាលំអិតនៅចំនុច៣.១ -៣.៥ ខាងក្រោម ។

## ៣.១. ការខូចខាត និងស្រកទំងន់

យោងតាមបទសំភាសន៍ជាមួយពាណិជ្ជករ និងការសង្កេតផ្ទាល់លើការដឹកជញ្ជូនត្រី អត្រាខូចខាត និងស្រកទំងន់មានប្រហែល ១០-១៥% នៃទំងន់ដឹកជញ្ជូនសរុប (១00-១៥0គ.ក/តោនត្រី) ចាប់ពីកន្លែងទិញនៅឯភូមិ/កន្លែងនេសាទ រហូតដល់កន្លែងលក់នៅមណ្ឌលបែងចែកផលនេសាទ ។ ការបាត់បង់ទាំងនេះបណ្តាលមកពីការបាត់បង់កាកសំណល់ក្នុងខ្លួនត្រី ការខូចត្រី ការហួតទឹក និងកត្តាផ្សេងទៀត សរុបប្រហែល ៥៥ដុល្លារ/តោន[៥] ។ អ្នកលក់រាយគ្មានរាយការណ៍ពីការខូចត្រី និងស្រកទំងន់ថែមទៀតទេ ក្នុងការដឹកជញ្ជូនត្រីចំងាយផ្លូវខ្លីពីមណ្ឌលបែងចែកទៅកាន់ទីផ្សារលក់រាយនៅភ្នំពេញ ។

ជាការប្រៀបធៀប អត្រាខូចខាតនិងស្រកទំងន់ ១០-១៥%សំរាប់ពាណិជ្ជកម្មត្រីពីបឹងទន្លេសាបទៅភ្នំពេញ វាខ្ពស់ប្រហែលបីដងជាង អត្រាប៉ាន់ស្មាន ៣-៥%សំរាប់ការនាំចេញត្រីពីបឹងទន្លេសាបទៅប្រទេសថៃ (Yim and McKenney 2003) ។ ពិនិត្យតាមការចំណាយពេលច្រើនជាងដើម្បីដឹកជញ្ជូន និងលើកដាក់រៀបចំត្រីសំរាប់នាំចេញគំហើញនេះគួរឱ្យភ្ញាក់ផ្អើលណាស់ ។ ប៉ុន្តែពាណិជ្ជករអ្នកនាំត្រីទៅភ្នំពេញលើកថា មូលហេតុសំខាន់នៃការខូចខាត និងស្រកទំងន់ច្រើនជាងនេះ គឺដោយសារត្រីដឹកទៅភ្នំពេញមានគុណភាពទាបជាង (ពោលគឺមិនសូវស្រស់) ជាងត្រីដឹកជញ្ជូនសំរាប់នាំចេញ ។ ដូច្នេះ គេអាចរំពឹងទុកបានថាការខូចខាត និងស្រកទំងន់ ត្រូវខ្ពស់ជាងជាមិនខាន ។

មានកត្តាច្រើនទៀតរួមចំណែកដល់ ការខូចខាត និងស្រកទំងន់ ប៉ុន្តែកត្តាទាំងនេះមានប្រហាក់ប្រហែលគ្នា (ឬធ្ងន់ធ្ងរជាង) ក្នុងការនាំចេញ ដូច្នេះវាមិនអាចពន្យល់ពីអត្រាខូចខាតខ្ពស់ជាងក្នុងពាណិជ្ជកម្មត្រីទៅភ្នំពេញទេ ។ កត្តាទាំងនេះរួមមានៈ ក) ការរក្សាត្រីប្រមូលទិញបានក្នុងធុងដាក់ទឹកកកយូរថ្ងៃពេក (ក្នុងរយៈពេលនេះត្រីចាប់ផ្តើមខូចគុណភាព) មុនពេលដឹកទៅភ្នំពេញ ខ) ការដឹកជញ្ជូនត្រីដោយរើវាចេញពីធុងទឹកកកនៅកន្លែងឡើងត្រី ទៅដាក់ក្នុងកញ្ជើឬស្បៃផ្ទុកលើរថយន្ត គ) ការលើកដាក់រៀបចំច្រើនដងក្នុងពេលរើត្រី និងផ្ទុកត្រីនៅតាមកន្លែងលក់ដូរផ្សេងៗក្នុងដំណើរការម៉ាឃីទីង ។

បន្ថែមលើការខូចខាត និងស្រកទំងន់ ដែលកើតមានចំពោះម៉ាឃីទីងត្រីទៅភ្នំពេញ, ការខូចត្រី (ឬការប្រឈមនឹងគ្រោះថ្នាក់ខូចត្រី) ធ្វើឱ្យខាតបង់តំលៃត្រីយ៉ាងច្រើននៅក្នុងពេលលក់រាយ ។ ដូចបានកំណត់សំគាល់ក្នុងចំណុច២.៣ អ្នកលក់រាយបញ្ចុះថ្លៃត្រីតាមពេលកន្លងទៅ ពីព្រោះអ្នកប្រើប្រាស់តែងគិតថា ត្រីកាន់តែអន់គុណភាព បើពេលវេលាវាកាន់តែថ្ងៃទៅ ឬល្ងាច

[៥] គួរសំគាល់ថា តួលេខប៉ាន់ស្មានពីការបាត់បង់នេះ គ្មានគិតពីបន្ទុកចំណាយទាក់ទិននឹងការថយចុះគុណភាពត្រីទេ (លើកលែងតែត្រីនោះត្រូវបោះចោល) ។ ការស្រាវជ្រាវនេះ ពុំមានលទ្ធភាពធ្វើវិភាគពីការប្រែប្រួលគុណភាពត្រី ឬក៏ការប៉ះពាល់ដល់ថ្លៃលក់រាយនៅភ្នំពេញដោយសារការប្រែប្រួលនេះទេ ។ ដូច្នេះបន្ទុកចំនាយពិតទាក់ទិននឹងការខូចខាតត្រី អាចខ្ពស់ជាងតួលេខប៉ាន់ស្មាន ៥៥ដុល្លារ/តោនទៅទៀត ។

ទៅ ។ ក្នុងករណីជាច្រើន ត្រីដែលនៅសល់រហូតដល់ពេលល្ងាច ឬមួយគេកែច្នៃ វាជាផលិតផលអ្វីមួយថោកជាង ឬមួយលក់ខាត ។ វិធីបញ្ចុះតំលៃត្រីលក់រាយនេះត្រូវតែប្រើប្រាស់ ពីព្រោះត្រីដែលដាក់តាំងលក់រាយ គេគ្មានដាក់ទឹកកកដើម្បីជួយរក្សាគុណភាពវាទេ ។ ដល់ពេលល្ងាចទៅ ត្រីបានបាត់បង់គុណភាពអស់យ៉ាងច្រើន ។



ត្រីទឹកសាប ដាក់តាំងលក់ ដោយគ្មាន ដាក់ទឹកកក នៅផ្សារធំថ្មី

ថ្វីបើអ្នកលក់រាយបានទទួលស្គាល់បញ្ហានេះ ប៉ុន្តែពួកគេនៅតែមិនប្រើទឹកកកដដែលនៅពេលតាំងត្រីលក់ ពីព្រោះអ្នកប្រើប្រាស់មើលឃើញទឹកកកជាសញ្ញាមួយបង្ហាញថា ត្រីមិនស្រស់ល្អទេ ។ ដោយសារគំនិតបែបនេះ អ្នកលក់រាយអះអាងថា មិនអាចប្រើទឹកកកបានទេ (ទោះជាទឹកកកថោក ឬល្អប្រសើរសំរាប់រក្សាត្រីឱ្យស្រស់ក្តី) ពីព្រោះអ្នកប្រើប្រាស់គេមិនទិញត្រី "មិនសូវស្រស់" របស់គាត់ទេ ។ បញ្ហាកាន់តែធ្ងន់ធ្ងរថែមទៀត ដោយសារសព្វថ្ងៃអ្នកលក់រាយតាំងត្រីលក់ដោយដាក់ទឹកកកតែកាលណាត្រីនោះអន់គុណភាពខ្លាំង ។ ទង្វើនេះកាន់តែពង្រឹងគំនិតរបស់អ្នកប្រើប្រាស់ថា ការប្រើទឹកកកមានន័យថាត្រីមិនស្រស់ទេ ។

មុនពេលត្រីទៅដល់អ្នកលក់រាយ គេប្រើទឹកកក ដើម្បីរក្សាគុណភាពត្រីទឹកសាបនៅគ្រប់ដំណាក់កាលម៉ាឃីទីង ។ នៅពេលពាណិជ្ជករទិញត្រីនៅបឹងទន្លេសាប គេស្តុកត្រីនៅក្នុងធុងទឹកកកភ្លាមៗ ។ បន្ទាប់មកគេដឹកត្រី ដោយដាក់ទឹកកកមកមណ្ឌលបែងចែក ។ នៅពេលអ្នកលក់រាយទិញត្រីនៅមណ្ឌលបែងចែក ពួកគេយកទឹកកកចេញមុនពេលដឹកវាទៅទីផ្សារលក់រាយ ដូច្នេះ ត្រីមានសីតុណ្ហភាពធម្មតាវិញនៅពេលដាក់តាំងលក់ ។ គ្មានការប្រើទឹកកកទេ ក្នុងពេលតាំងលក់ពេញមួយថ្ងៃ ។ ប៉ុន្តែបើសិនអ្នកលក់រាយសំរេចទុកត្រីលក់ព្រឹកស្អែក ត្រីទាំងនោះត្រូវរក្សាទុកក្នុងទឹកកកពេញមួយយប់ ។ លុះព្រឹកឡើងទឹកកកត្រូវយកចេញ មុនពេលដាក់តាំងលក់ជាថ្មីម្តងទៀត ។



ត្រីមកពីបឹងទន្លេសាបដាក់ក្នុងទឹកកក នៅមណ្ឌលបែងចែកផលនេសាទច្រាំងចំរេះ សំរាប់លក់ឱ្យអ្នកលក់រាយ

ស្រដៀងគ្នានឹងការលក់ត្រីទឹកសាបមកពីបឹងទន្លេសាបដែរ ទឹកកកត្រូវបានប្រើប្រាស់ក្នុងគ្រប់ដំណាក់កាល ម៉ាឃីទីងត្រីទឹកប្រៃតាំងពីឆ្នេរសមុទ្រមកដល់ភ្នំពេញ ។ ប៉ុន្តែខុសពីត្រីទឹកសាប អ្នកលក់រាយនៅទីផ្សារភ្នំពេញដាក់តាំងត្រីទឹកប្រៃលក់ដោយដាក់ទឹកកក ។ អ្នកលក់រាយប្រាប់ថា អ្នកប្រើប្រាស់ធ្លាប់ឃើញជាធម្មតាហើយនូវការប្រើប្រាស់ទឹកកកសំរាប់រក្សា និងដាក់តាំងត្រីទឹកប្រៃ ។ អ្នកប្រើប្រាស់យល់ថា ត្រីទឹកប្រៃចាប់បាននៅឆ្ងាយពីភ្នំពេញ ដូច្នេះត្រូវតែរក្សាវាក្នុងទឹកកកដើម្បីរក្សាភាពស្រស់ ។ ការយល់ឃើញនេះធ្វើឱ្យអ្នកលក់រាយអាចប្រើទឹកកកអាចរក្សាគុណភាពត្រី និងរក្សាថ្លៃត្រីទឹកប្រៃឱ្យមានស្ថិរភាពពេញៗមួយថ្ងៃ ។ ផ្ទុយទៅវិញ អ្នកប្រើប្រាស់ត្រីទឹកសាបគិតថា ត្រីទឹកសាបចាប់នៅកន្លែងជិតៗ ដឹកមកផ្សារភ្លាមៗ និងលក់ស្រស់ៗដោយមិនបាច់ត្រូវការទឹកកក ។ ថ្វីបើ ការយល់ឃើញបែបនេះអាចពិតមែនកាលពីដើម ប៉ុន្តែសព្វថ្ងៃវាលែងត្រឹមត្រូវទៀតហើយ ។



ត្រីទឹកប្រៃដាក់តាំងលក់ដោយរក្សានៅក្នុងទឹកកក នៅផ្សារធំថ្មី

## ៣.២. ការកាន់កាប់ផ្តាច់មុខនៃមណ្ឌលបែងចែកត្រី

ច្រកចូលចំបងនិមួយៗសំរាប់ពាណិជ្ជកម្មត្រីទៅភ្នំពេញ គឺរ៉ាប់រងដោយមណ្ឌលបែងចែកផលនេសាទមានអាជ្ញាប័ណ្ណមួយ ។ ត្រីដែលធ្វើពាណិជ្ជកម្មពីភាគខាងត្បូងបឹងទន្លេសាបទៅភ្នំពេញតាមផ្លូវជាតិលេខ៥ ត្រូវបានបែងចែកតាមរយៈមណ្ឌលបែងចែក

ផលនេសាទនៅច្រាំងចំរេះ ។ ដូចគ្នានេះដែរ ត្រីដឹកតាមផ្លូវទឹកពីភាគខាងត្បូងបឹងទន្លេសាបទៅភ្នំពេញ ត្រូវបានបែងចែកតាមរយៈកំពង់ផែបែងចែកផលនេសាទភ្នំពេញ ។ ចំពោះត្រីដែលធ្វើពាណិជ្ជកម្មពីភាគខាងត្បូងទៅភ្នំពេញ គេដឹកតាមផ្លូវជាតិលេខ១ និងបែងចែកតាមរយៈមណ្ឌលបែងចែកផលនេសាទច្បារអំពៅ ។ គ្មានមណ្ឌលបែងចែកផលនេសាទណាផ្សេងដែលបានទទួលការអនុញ្ញាតឱ្យដំណើរការដោយស្របច្បាប់ក្នុងតំបន់ទាំងនេះទេ ។

ប្រាក់កំរៃនៅមណ្ឌលបែងចែកផលនេសាទ បានកំណត់ ៣% នៃចំណូលលក់នៅមណ្ឌល ច្រាំងចំរេះ និងច្បារអំពៅ និង ៥%នៃចំណូលលក់នៅផែបែងចែលផលនេសាទរាជធានីភ្នំពេញ ។ ពាណិជ្ជករតវ៉ាថា ប្រាក់កំរៃនេះខ្ពស់យ៉ាងច្រើនជាងនៅឯមណ្ឌលបែងចែកផលនេសាទក្រៅផ្លូវការ (គ្មានអាជ្ញាប័ណ្ណ) ក្នុងតំបន់នោះ ។ ឧទាហរណ៍ ពាណិជ្ជករបង់ប្រាក់កំរៃជាមធ្យម ២២ដុល្លារ/តោន លើបរិមាណលក់នៅច្រាំងចំរេះ ។ ជាការប្រៀបធៀបមណ្ឌលបែងចែកផលនេសាទគ្មានអាជ្ញាប័ណ្ណយកតែប្រាក់កំរៃចំណត ៣.០០០-៥.០០០រៀល (ប្រហែល ១ដុល្លារ) ក្នុងត្រីមួយរថយន្តតូច ឬរថយន្តកន្ទុយកាត់ ។ បរិមាណត្រីធ្វើពាណិជ្ជកម្មនៅមណ្ឌលទាំងនេះច្រើនតែមានបរិមាណតិចជាង (ប្រហែល ៣០០-៥០០គ.ក) ដើម្បីជៀសវាងការចាប់អារម្មណ៍ពីមន្ត្រីមានសមត្ថកិច្ច ។ ដូច្នេះបើគិតសំរាប់ត្រីមួយតោនដូចគ្នា ប្រាក់កំរៃគឺប្រហែល ២-៣ដុល្លារ ដែលត្រូវជា ១ភាគ១០ នៃប្រាក់កំរៃយកនៅច្រាំងចំរេះ ។ ប៉ុន្តែ ដោយសារពាណិជ្ជករទទួលការព្រមានថា នឹងត្រូវផាកពិន័យបើសិនប្រើប្រាស់មណ្ឌលបែងចែកគ្មានអាជ្ញាប័ណ្ណ សកម្មភាពពាណិជ្ជកម្មនៅទីនោះមានកំរិតទាប (តិចជាង ១.០០០តោន/ឆ្នាំ/មណ្ឌល) ។ ជាការប្រៀបធៀបមណ្ឌលច្រាំងចំរេះទទួលបែងចែកផលនេសាទ ដល់ទៅជាង ១៥.០០០តោនត្រី/ឆ្នាំ[៦] ។

មណ្ឌលច្រាំងចំរេះ និងមណ្ឌលគ្មានអាជ្ញាប័ណ្ណ ផ្តល់សេវាប្រហាក់ប្រហែលគ្នាគឺ ទឹក អគ្គិសនី ទីលានចាក់បេតុងសំរាប់ធ្វើពាណិជ្ជកម្ម និងកំលាំងពលកម្មរើត្រីពីរថយន្ត[៧] ។ ប៉ុន្តែនៅច្រាំងចំរេះ ហាក់ដូចមានបញ្ហាទំនាស់គ្នាខ្លះពីរឿង អ្នកណាទទួលខុសត្រូវផ្តល់ (ឬបង់ថ្លៃ) សេវាទាំងនេះ គឺអ្នកបែងចែកលើកថា ម្ចាស់មណ្ឌលជាអ្នកទទួលខុសត្រូវផ្តល់កំលាំងរើត្រីពីរថយន្ត និងទូទាត់ថ្លៃអគ្គិសនី និងទឹក ប៉ុន្តែក្នុងការអនុវត្តន៍ជាក់ស្តែង អ្នកបែងចែកផ្តល់កំលាំងពលកម្មភាគច្រើន និងបង់ថ្លៃទឹក និងអគ្គិសនីថែមទៀត[៨] ។ ដោយពាណិជ្ជករមានការពឹងផ្អែកលើអ្នកបែងចែក ដូច្នេះអ្នកបែងចែកប្រហែលជាផ្ទេរចំណាយនេះទៅពាណិជ្ជករតាមរយៈការផ្តល់ហិរញ្ញប្បទាន និងការយកកំរៃសេវាខ្ពស់ (ហើយក្នុងហេតុផលដូចគ្នា ពាណិជ្ជករប្រហែលផ្ទេរចំនាយទាំងនេះទៅអ្នកនេសាទជាបន្ត) ។

## ៣.៣. ប្រាក់កំរៃយកតាមផ្លូវពាណិជ្ជកម្ម

ក្នុងម៉ាឃីទីងត្រីតាមផ្លូវគោកពីបឹងទន្លេសាប (កំពង់លួង) ទៅភ្នំពេញ, ពាណិជ្ជករត្រូវបង់ប្រហែល ៩ដុល្លារ/តោនទៅឱ្យក្រុមហ៊ុនវិនិយោគផ្លូវនៅជិតកន្លែងឡើងត្រីកំពង់លួង និងកន្លែងកុងត្រូលមួយនៅព្រំប្រទល់ខេត្តពោធិសាត់និងកំពង់ឆ្នាំង ។ មូលដ្ឋានច្បាប់ និង/ឬសិទ្ធិអំណាចសំរាប់ប្រមូលប្រាក់កំរៃនេះមិនអាចកំណត់ឃើញទេ ។ បន្ថែមលើប្រាក់កំរៃនេះ ពាណិជ្ជករ

---

៦ ការប៉ាន់ស្មាននេះ ផ្អែកលើការគុណគួរ (extrapolation) ចេញពីពតិមានពាណិជ្ជកម្ម/ចំណូលលក់ ផ្តល់ដោយអ្នកបែងចែក ៧នាក់ ក្នុងចំនោម ១៨នាក់ដែលដំណើរការនៅច្រាំងចំរេះ ។ ដោយអ្នកបែងចែកអាចមានផលប្រយោជន៍ដើម្បីរាយការណ៍មិនពិតពីតួលេខលក់ ដូច្នេះតួលេខនេះគួរចាត់ទុកជាការប៉ាន់ស្មានអប្បរមានៃសកម្មភាពបែងចែក ។

៧ មណ្ឌលបែងចែកគ្មានអាជ្ញាប័ណ្ណមួយ សព្វថ្ងៃគ្មានទីលានចាក់បេតុងសំរាប់ធ្វើពាណិជ្ជកម្មទេ ហើយចង់ធ្វើវិនិយោគកែលំអសេវានេះ ។ ប៉ុន្តែដោយការលំបាកក្នុងការសុំសេចក្តីអនុញ្ញាតធ្វើវិនិយោគ និងការបារម្ភពីរឿងប្រាក់កំរៃខ្ពស់ហួសលទ្ធភាពបង់ ម្ចាស់មណ្ឌលក៏បានបោះបង់ចោលគំរោងវិនិយោគដ៏មានសក្តានុពលនេះ ។

៨ អ្នកបែងចែកអះអាងថា ការតំរូវទាំងនេះមានបញ្ជាក់ក្នុង "សៀវភៅបន្ទុក" របស់មណ្ឌលរួចហើយ គឺសៀវភៅដែលចែងពីលក្ខខណ្ឌនៃកិច្ចព្រមព្រៀងរវាងអ្នកបែងចែកនិងម្ចាស់មណ្ឌល។ វបសអ មិនអាចរកបានសៀវភៅបន្ទុកនៃមណ្ឌលច្រាំងចំរេះដើម្បីផ្ទៀងផ្ទាត់ពតិមាននេះទេ។

តម្លៃត្អូញត្អែរថា នៅពេលពួកគេចង់ដឹកត្រីម្តងៗត្រង់ទៅមណ្ឌលបែងចែកត្រីច្បារអំពៅផ្ទាល់ ពួកគេត្រូវតែឈប់នៅច្រាំងចំរេះ និងបង់ប្រាក់កំរៃ (ប្រហែល ៥ដុល្លារមួយរថយន្តកន្ទុយកាត់) ទោះបី ពួកគេមិនប្រើប្រាស់សេវាក្តី ហើយត្រូវបង់ប្រាក់កំរៃឱ្យមណ្ឌលច្បារអំពៅពេញថ្លៃ (៣% នៃចំណូលលក់) ។

ប្រាក់កំរៃលើពាណិជ្ជកម្មត្រីពីបឹងទន្លេសាបទៅភ្នំពេញ វាទាបយ៉ាងច្រើនជាងប្រាក់កំរៃយកលើការនាំចេញត្រីពីបឹងទន្លេសាបទៅប្រទេសថៃ (៨៣ដុល្លារ/តោន) (Yim and McKenney 2003) ។ រឿងនេះហាក់ដូចមានមូលហេតុចំបងបី ។ ទីមួយ ជាងពាក់កណ្តាលនៃប្រាក់កំរៃយកលើការនាំត្រីចេញ ត្រូវបង់នៅព្រំប្រទល់កម្ពុជាថៃ ។ ទីពីរ ថ្វីបើត្រូវមានលិខិតអនុញ្ញាតដឹកជញ្ជូន ដើម្បីធ្វើការជញ្ជូនត្រី យោងតាមការតំរូវនៅក្នុងអនុក្រឹត្យស្តីពីការដឹកជញ្ជូនផលនេសាទ (លេខ ៦៦ អនក្រ ចុះថ្ងៃទី ៥ វិច្ឆិកា ១៩៨៨) ប៉ុន្តែការតំរូវនេះហាក់ដូចជាអនុវត្តតែលើការដឹកជញ្ជូនត្រីសំរាប់នាំចេញប៉ុណ្ណោះ (ហើយជារឿយៗបានក្លាយជាមូលដ្ឋានសំរាប់ការប្រមូលប្រាក់កំរៃក្រៅផ្លូវការ) ។ ត្រីធ្វើពាណិជ្ជកម្មក្នុងប្រទេសកម្ពុជា មិនត្រូវការឱ្យមានលិខិតអនុញ្ញាតដឹកជញ្ជូនទេ ។ ក្នុងករណីភាគច្រើន មន្ត្រីប្រមូលប្រាក់កំរៃអាចសំគាល់ញែកគ្នាបាន រវាងការដឹកជញ្ជូនសំរាប់ទីផ្សារក្នុងស្រុក និងសំរាប់ការនាំចេញ ពីព្រោះពួកគេស្គាល់ពាណិជ្ជករក្នុងស្រុក និងអ្នកនាំចេញច្បាស់ ។ នៅពេលពួកគេមិនដឹងច្បាស់ ពួកគេសំរេចអារកាត់ដោយពិនិត្យលើផ្លូវពាណិជ្ជកម្ម មធ្យោបាយដឹកជញ្ជូន និង/ឬប្រភេទត្រីកំពុងដឹក ។ ហេតុផលចុងក្រោយគឺប្រាក់កំរៃមានកំរិតទាបជាងសំរាប់ពាណិជ្ជកម្មក្នុងស្រុក ពីព្រោះត្រីលក់ដូរក្នុងស្រុកច្រើនមានគុណភាពទាបជាងត្រីនាំចេញ ។ ដោយសារប្រាក់កំរៃ (ក្រៅផ្លូវការ) តែងកើនឡើងតាមតំលៃប៉ាន់ស្មាននៃត្រីដឹកជញ្ជូន គេអាចរំពឹងថា ប្រាក់កំរៃដាក់ស្លែងលើពាណិជ្ជកម្មត្រីក្នុងស្រុក វាត្រូវតែតិចជាងប្រាក់កំរៃលើការនាំចេញត្រី ។

## ៣.៤. ចំណាយដឹកជញ្ជូន និងទឹកកក

បន្ថែមពីលើចំណាយទាក់ទិននឹងការខូចត្រីនិងស្រកទំងន់ ប្រាក់កំរៃមណ្ឌលបែងចែក និងប្រាក់កំរៃបង់ឱ្យផ្លូវ/កុងត្រូលពាណិជ្ជករមានចំណាយទាក់ទិននឹងប្រតិបត្តិការពាណិជ្ជកម្មផ្សេងៗ ដូចជា ការដឹកជញ្ជូន ទឹកកក កំលាំងពលកម្ម និងសំភារៈបរិក្ខារ ។ ចំណាយទាំងនេះមានប្រហែល ១៣៥ដុល្លារ/តោន ចំពោះពាណិជ្ជកម្មពីកំពង់លួង និងកំពង់ឆ្នាំង ទៅមណ្ឌលបែងចែកច្រាំងចំរេះ ហើយការដឹកជញ្ជូន និងទឹកកក តំណាងឱ្យប្រហែល ៩០% នៃចំណាយទាំងនេះ ។ ក្នុងករណីភាគច្រើន ពាណិជ្ជករដឹកជញ្ជូនត្រីជាពីរដំណាក់កាលគឺ តាមទូកពីភូមិ/កន្លែងនេសាទ ទៅកន្លែងឡើងត្រី និងតាមរថយន្ត ពីកន្លែងឡើងត្រីទៅមណ្ឌលបែងចែក ។ ចំណាយមធ្យមលើការដឹកជញ្ជូនត្រីទាំងពីរដំណាក់កាល រួមទាំង ចំណាយរំលស់ទូក ប្រេងឥន្ធនៈ និងចំណាយជួលរថយន្តផង អស់ប្រហែល ៦៤ដុល្លារ/តោន ។

ការរក្សាគុណភាពត្រីក្នុងពេលប្រមូលទិញ ស្តុកទុក និងដឹកជញ្ជូន. ត្រូវការប្រើទឹកកកយ៉ាងច្រើន ។ ត្រីទិញ បានអាចត្រូវស្តុកទុកក្នុងទឹកកកអស់ប្រហែលពីរបីថ្ងៃ និងដឹកពីកន្លែងឡើងត្រីទៅមណ្ឌលបែងចែកត្រីអស់ច្រើនម៉ោងទៀត (រួមទាំងលើកដាក់ពីរថយន្តផង) ។ ចាប់ពីការទិញត្រីនៅកន្លែងនេសាទ រហូតដល់ពេលវេលាត្រីចុះនៅមណ្ឌលបែងចែកពាណិជ្ជករប្រើទឹកកកអស់ប្រហែល ៣តោនសំរាប់ត្រីមួយតោន ។ ដោយទឹកកកមានថ្លៃពី ១៦-១៩ដុល្លារ/តោននៅកំពង់លួង និងទីរួមខេត្តកំពង់ឆ្នាំង. ដូច្នេះចំណាយលើទឹកកកជាមធ្យមអស់ប្រហែល ៥៦ដុល្លារ /តោនត្រីធ្វើពាណិជ្ជកម្ម[៩] ។

---

[៩] ការប៉ាន់ស្មាននេះពឹងផ្អែកលើកំរិតថ្លៃទូទៅនៅពេលស្រាវជ្រាវ (ធ្នូ ២០០២) ។ ថ្មីៗនេះគេរាយការណ៍ថា ថ្លៃទឹកកកនៅទីរួមខេត្តកំពង់ឆ្នាំងឡើងដល់ ៣០ដុល្លារ/តោន ។ រឿងនេះកើតឡើងដោយសារការធ្វើអាជីវកម្មផ្តាច់មុខ និងការរារាំងចំពោះពាណិជ្ជកម្មទឹកកកទទួលមកពីអ្នកផលិតទឹកកកនៅខេត្តកំពង់ស្ពឺ ដែលលក់ទឹកកកថ្លៃត្រឹមតែ ១៥ដុល្លារ/តោន (Cambodia Daily 16 October 2003) ។

## ៣.៥. ចំណាយហិរញ្ញប្បទាន

ដូចបានពិភាក្សាក្នុងចំណុច២.៣ អ្នកបែងចែកដើរតួនាទីសំខាន់ក្នុងការផ្តល់ហិរញ្ញប្បទានឱ្យទៅពាណិជ្ជករ ដើម្បីដោះស្រាយការទិញត្រី និងចំណាយប្រតិបត្តិការ ។ គ្មានអត្រាការប្រាក់យកជាផ្លូវការលើហិរញ្ញប្បទាននេះទេ ប៉ុន្តែអ្នកបែងចែកទាញយកផលពីប្រាក់កំចីរបស់ខ្លួនវិញតាមរយៈ "កំរៃជើងសារ" តិចឬច្រើនលើរាល់ចំណូលលក់ ។ កង្វះតំលាភាពលើបន្ទុកចំនាយកំចីអាចធ្វើឱ្យលំបាកដល់ពាណិជ្ជករក្នុងការ "ជ្រៃថ្លៃ" នៅពេលពួកគេស្វែងរកកំចី ។ ប៉ុន្តែតាមទិន្នន័យបានពីបទសំភាសន៍ជាមួយអ្នកបែងចែក ៧នាក់ ការយកការប្រាក់បង្កប់នេះហាក់ដូចមានកំរិតពី ៥០-១២០% ។ នេះជាចំណូលប៉ាន់ស្មានកាត់បន្ទុកចំណាយរួចហើយដែលបានដល់អ្នកបែងចែក ប៉ុន្តែសេវាអរូបិយខ្លះ មិនអាចកាត់ចេញបានទេ (ឧ. ផ្តល់ពតិមានពីថ្លៃ និងជួយចរចាថ្លៃឱ្យពាណិជ្ជករ)[១០] ។

ទំនាក់ទំនងចងគ្នាជាប់រវាងអ្នកបែងចែក និងពាណិជ្ជករ ធ្វើឱ្យពាណិជ្ជករលក់ត្រីតែតាមរយៈអ្នកបែងចែកនោះឯង ។ ថ្វីបើអ្នកបែងចែកជួបហានិភ័យខ្លះៗ ដោយពាណិជ្ជករបាត់មុខលែងមកសងបំណុលវិញ ប៉ុន្តែហានិភ័យនេះហាក់ដូចអាចកាត់បន្ថយបានច្រើនគ្រប់គ្រាន់ដែរដោយសារទំនាក់ទំនងយូរអង្វែងរវាងអ្នកបែងចែក និងពាណិជ្ជករ និងការប្រើប្រាស់ក្នុងពេលថ្មីៗនូវកិច្ចសន្យាកំចីជាលាយលក្ខ័អក្សរ ។ អ្នកបែងចែកប្រាប់ថា ពួកគេមានការខាតបង់ច្រើនកាលពីពីរបីឆ្នាំមុន (១.000-២.000 ដុល្លារ/ឆ្នាំ) ប៉ុន្តែឥឡូវនេះ ការខាតបង់លើកំចីវាចោទបញ្ហាម្តងម្កាលទេ ។ ក្នុងម៉ាឃីទីងត្រី ពាណិជ្ជករហាក់ដូចមានហានិភ័យច្រើនជាងអ្នកបែងចែក ។ ពាណិជ្ជកររ៉ាប់រងហានិភ័យទាំងអស់នៃការប្រែប្រួលថ្លៃ ការខូចត្រី ការប្រែប្រួលប្រាក់កំរៃ និងការលំបាកផ្នែកប្រតិបត្តិការ ។ ផ្ទុយទៅវិញ អ្នកបែងចែកទទួលប្រាក់កំរៃតាមបរិមាណត្រីលក់តាមរយៈតូបរបស់ខ្លួន ដោយមិនគិតថា ពាណិជ្ជករបានចំណេញ ឬត្រូវខាតបង់ទេ ។

[១០] កាត់ចំណាយរួចហើយ អ្នកបែងចែកធុនមធ្យមរកចំណូលបាន ១៨ដុល្លារ/តោនត្រីលក់តាមរយៈតូបរបស់ពួកគេ ។

# ជំពូក ៤

# សេចក្តីសន្និដ្ឋាន និងអនុសាសន៍

ម៉ាឃីទីងត្រីពីបឹងទន្លេសាបទៅដល់ភ្នំពេញ មានប្រតិបត្តិការពាណិជ្ជកម្មបីសំខាន់ៗគឺ ការលក់ពីអ្នកនេសាទទៅឱ្យពាណិជ្ជករ ការលក់ពីពាណិជ្ជករទៅអ្នកលក់រាយតាមរយៈអ្នកបែងចែក និងការលក់ពីអ្នកលក់រាយទៅអតិថិជន ។ អ្នកបែងចែកដើរតួនាទីជាគន្លឹះក្នុងរចនាសម្ព័ន្ធទីផ្សារ ប៉ុន្តែសំខាន់មិនមែនក្នុងការងារ "បែងចែក" ទេ តែក្នុងការងារផ្តល់ហិរញ្ញប្បទានទៅវិញ ។ អ្នកបែងចែកផ្តល់ទុនឱ្យពាណិជ្ជករខ្ចីដើម្បីទិញត្រី និងទ្រទ្រង់សកម្មភាពពាណិជ្ជកម្ម ហើយពាណិជ្ជករឱ្យអ្នកនេសាទខ្ចីទុននេះខ្លះបន្ត សំរាប់ទិញឧបករណ៍នេសាទ និងធ្វើចំនាយផ្សេងៗ ។ លក្ខខណ្ឌក្នុងកំចីទាំងនេះគឺ អ្នកនេសាទត្រូវលក់ត្រីទាំងអស់ទៅឱ្យពាណិជ្ជករជាម្ចាស់បំណុល ហើយពាណិជ្ជករក៏ត្រូវលក់ត្រីទាំងអស់តាមរយៈអ្នកបែងចែកជាម្ចាស់បំណុលខ្លួនដែរ និងបង់ "ប្រាក់កំរៃ" ជាប់ទាក់ទិន ។ ទំនាក់ទំនងចងគ្នានេះ ឃើញមានជាទូទៅក្នុងពាណិជ្ជកម្មត្រីពីបឹងទន្លេសាបទៅភ្នំពេញ ដែលអ្នកនេសាទភាគច្រើនជំពាក់បំណុលពាណិជ្ជករ ហើយពាណិជ្ជករភាគច្រើនជំពាក់បំណុលអ្នកបែងចែក ។

ខណៈដែលរចនាសម្ព័ន្ធទីផ្សារបច្ចុប្បន្ន ជួយទ្រទ្រង់ឱ្យពាណិជ្ជកម្មត្រីមានស្ថិរភាព ប៉ុន្តែវាមានចំណុចអវិជ្ជមានច្រើនដែរ ។ ទីមួយ អ្នកនេសាទភាគច្រើនមានជំហរខ្សោយក្នុងការចរចាថ្លៃ: ពួកគេត្រូវតែលក់ត្រីទៅឱ្យពាណិជ្ជករជាម្ចាស់បំណុល ។ ទីពីរ កង្វះតំលាភាពអំពីអត្រាការប្រាក់លើកំចី (ពីព្រោះគេបង្កប់វានៅក្នុងកំរិតថ្លៃបញ្ចុះទាប ដែលពាណិជ្ជករទិញត្រីពីអ្នកនេសាទ និងក្នុងមួយភាគនៃ "ប្រាក់កំរៃ" ដែលពាណិជ្ជករបង់ឱ្យអ្នកបែងចែកលើគ្រប់ចំណូលលក់) ដែលធ្វើឱ្យគេពិបាកធ្វើការវាយតំលៃពីបន្ទុកចំណាយហិរញ្ញប្បទានពិត ។ ម្ចាស់បំណុលប្រហែលឆ្លៀតយកប្រយោជន៍លើកង្វះតំលាភាពនេះ ដើម្បីបង្កើនចំណូលអំពីកំចីរបស់ខ្លួន ។

បន្ថែមលើចំនាយហិរញ្ញប្បទានខ្ពស់ ម៉ាឃីទីងត្រីជួបឧបសគ្គជាច្រើនទៀត ដូចជាការខូចត្រី ការស្រកទំងន់ ការកាន់កាប់បែបផ្តាច់មុខលើការបែងចែក ចំណាយដឹកជញ្ជូននិងទឹកកក និងប្រាក់កំរៃផ្សេងៗយកតាមផ្លូវ ។ ចំណាយម៉ាឃីទីងសរុបជាមធ្យមគឺ ៣០៨ដុល្លារ/តោនត្រី ពីបឹងទន្លេសាប (ឆ្លងកាត់តាមមណ្ឌលបែងចែកផលនេសាទច្រាំងចំរេះ) ទៅទីផ្សារលក់រាយនៅភ្នំពេញ។ ជាលទ្ធផល ចំនួលម៉ាឃីទីងតំណាងឱ្យ ៦៥-៧៥% នៃថ្លៃត្រីលក់រាយ ឯអ្នកនេសាទទទួលបានតែ២៥-៣៥%ប៉ុណ្ណោះ ។ ដើម្បីកែលំអជីវភាពអ្នកនេសាទតាមរយៈការបង្កើនចំណូលពីការចាប់ត្រី ត្រូវអនុវត្តវិធានការជាជំហានៗ ដើម្បីកាត់បន្ថយចំណាយម៉ាឃីទីង និងអប្រសិទ្ធិភាពផ្សេងៗ ។ ក្នុងគោលដៅនេះ ការសិក្សាបានផ្តល់អនុសាសន៍មួយចំនួនដូចតទៅសំរាប់ជាជំនួយដល់ការពិចារណា ។

១) បញ្ចូលការប្រកួតប្រជែងទៅក្នុងសេវាបែងចែកត្រី ដោយផ្តល់អាជ្ញាប័ណ្ណបន្ថែមសំរាប់មណ្ឌលបែងចែកត្រី

ពាណិជ្ជករ និងអ្នកបែងចែកជាច្រើនត្អូញត្អែរថា ប្រាក់កំរៃមណ្ឌលបែងចែកមានកំរិតខ្ពស់ពេក បើពិនិត្យតាមកង្វះខាតសេវាផ្តល់ឱ្យ ។ ប៉ុន្តែដោយសារផ្លូវពាណិជ្ជកម្មចំបងនិមួយៗគឺមានមណ្ឌលតែមួយសំរាប់បំរើឱ្យគោលដៅភ្នំពេញ ដូច្នេះពាណិជ្ជករ និងអ្នកបែងចែកគ្មានកន្លែងផ្សេង (ស្របច្បាប់) ណាផ្សេង ដែលពួកគេអាចធ្វើប្រតិបត្តិការពាណិជ្ជកម្មត្រីបានទេ ។ ដោយគ្មានការប្រកួតប្រជែងមណ្ឌលបែងចែកមានអាជ្ញាប័ណ្ណ គឺគ្មានអ្វីជំរុញច្រើនទេ ដើម្បីឱ្យចុះថ្លៃ ឬកែលំអ

សេវាឡើង ។ ការស្រាវជ្រាវសំរាប់ការសិក្សានេះ បានរកឃើញមណ្ឌលបែងចែកផលនេសាទគ្មានអាជ្ញាប័ណ្ណជាច្រើន ដែលកំពុងដំណើរការក្រៅផ្លូវការនៅក្រៅក្រុងភ្នំពេញ ក្នុងនេះមានមួយចំនួនចង់ដំណើរការស្របច្បាប់ដែរ ប៉ុន្តែមិនអាចសុំអាជ្ញាប័ណ្ណបាន ។ មណ្ឌលទាំងនេះគួរទទួលបានអាជ្ញាប័ណ្ណ (តាមអត្រាអាចបង់បាន) ដើម្បីឱ្យមានការប្រកួតប្រជែងនៅក្នុងសេវាបែងចែកត្រី ។ ការប្រកួតប្រជែងបែបនេះ អាចកែលំអលក្ខខណ្ឌទីផ្សារ ដោយសង្កត់បញ្ចុះប្រាក់កំរៃយកដោយមណ្ឌលបែងចែក ព្រមទាំងលើកទឹកចិត្តឱ្យបំរើសេវាកាន់តែប្រសើរ ។

២) ធ្វើយុទ្ធនាការផ្លាស់ប្តូរគំនិតអ្នកហូបត្រីអំពី ការប្រើទឹកកក និងភាពស្រស់នៃត្រីទឹកសាប នៅទីផ្សារលក់រាយ

ការខូចខាត (ឬការគំរាមកំហែងនៃការខូចខាត) ត្រីទឹកសាបបណ្តាលឱ្យបាត់បង់តំលៃត្រីយ៉ាងច្រើននៅទីផ្សារលក់រាយ ។ ថ្វីបើត្រីទឹកសាបបានស្តុកទុកច្រើនថ្ងៃ ហើយដឹកជញ្ជូនដោយរក្សាក្នុងទឹកកកក្តី ប៉ុន្តែអ្នកលក់រាយដាក់តាំងត្រីលក់ដោយគ្មានទឹកកកទេ ។ ផ្ទុយទៅវិញ ត្រីទឹកប្រៃគេដាក់តាំងលក់ដោយរក្សាក្នុងទឹកកក ទោះបីមានលក្ខខណ្ឌដឹកជញ្ជូន និងរក្សាទុកប្រហាក់ប្រហែលគ្នាក្តី ។ អ្នកលក់រាយយកទឹកកកចេញពីត្រីទឹកសាប ពីព្រោះអ្នកប្រើប្រាស់តែងគិតថា វត្តមានទឹកកកបញ្ជាក់ពីភាពមិនស្រស់របស់ត្រី ។ ការធ្វើសេចក្តីប្រកាសជាសាធារណៈអាចជួយផ្លាស់ប្តូរគំនិតនេះ ដោយធ្វើការអប់រំអ្នកប្រើប្រាស់ត្រីពីការពិតជាក់ស្តែងក្នុងពាណិជ្ជកម្មៈ ពីព្រោះស្រដៀងគ្នានឹងត្រីទឹកប្រៃដែរ ត្រីទឹកសាបដែលពួកគេបរិភោគ ចាប់បាននៅឆ្ងាយពីទីក្រុងភ្នំពេញ ហើយរក្សាក្នុងទឹកកកជាច្រើនថ្ងៃ មុនពេលមកដល់ទីផ្សារលក់រាយ ។ តាមរយៈយុទ្ធនាការលើកកំពស់ការយល់ដឹងនៅទីផ្សារលក់រាយក្នុងស្រុក អ្នកទិញត្រីអាចទទួលស្គាល់ថា ទឹកកកដាក់រក្សាត្រីទឹកសាបដែលតាំងលក់គឺជាអាំងឌីកាទ័រនៃភាពស្រស់ មិនមែនគុណភាពអន់ទេ ។ ការផ្លាស់ប្តូរគំនិតនេះអាចឱ្យអ្នកលក់រាយត្រីប្រើទឹកកកបាន ដែលអាចជួយកាត់បន្ថយការខូចខាត រក្សាតំលៃត្រី និងកែលំអគុណភាព ។ ការកែលំអនេះនឹងរួមចំណែកធ្វើឱ្យថ្លៃត្រីទឹកសាបមានលំនឹង (ដូចក្នុងករណីត្រី ទឹកប្រៃដែលដាក់តាំងលក់ដោយដាក់ទឹកកក) ។

៣) ធ្វើការស្រាវជ្រាវបច្ចេកទេសបន្ថែមទៀត លើបញ្ហាខូចខាតនៅក្នុងប្រព័ន្ធម៉ាឃីទីងត្រី ពីកន្លែងឡើងត្រីរហូតដល់មណ្ឌលបែងចែកផលនេសាទ

ការខូចខាត និងស្រកទំងន់ប្រហែល ១០-១៥%នៃទំងន់ត្រីដឹកជញ្ជូន នៅក្នុងម៉ាឃីទីងត្រីពីកន្លែងនេសាទទៅមណ្ឌលបែងចែក, គឺជាការខាតបង់ដ៏ធំមួយ (៩៥ដុល្លារ/តោន) ។ មានកត្តាជាច្រើនដែលរួមចំណែកបង្កការខាតបង់នេះ គឺមានការប្រើទឹកកកមិនគ្រប់គ្រាន់ដោយអ្នកនេសាទមួយចំនួនក្នុងការរក្សាត្រីចាប់បាន, ការស្តុកទុកត្រីដោយពាណិជ្ជកររហូតដល់មួយសប្តាហ៍ មុនពេលដឹកទៅមណ្ឌលបែងចែក ការដឹកត្រីក្នុងកញ្ជេឫស្សី ដោយមិនប្រើធុងទឹកកក និងការលើដាក់រៀបចំច្រើនដងនៅក្នុងដំណើរការម៉ាឃីទីង ។ ប៉ុន្តែបើសិនគ្មានការស្រាវជ្រាវបន្ថែម ថាតើរបៀបស្តុកទុក និងលើកដាក់រៀបចំនេះ វាប៉ះពាល់យ៉ាងណាដល់គុណភាពត្រី, គេពិបាកនឹងកំណត់បានថា បញ្ហាណាមួយវារួមចំណែកខ្លាំងជាងគេដល់ការបង់ខាតដោយខូចត្រី ឬក៏មានវិធីអ្វីសំរាប់ដោះស្រាយបញ្ហានោះឱ្យបានប្រសើរបំផុត ។

៤) កំណត់ពីភាពស្របច្បាប់នៃការបង់ប្រាក់កំរៃបច្ចុប្បន្នតាមផ្លូវពាណិជ្ជកម្មត្រីក្នុងស្រុក និងលុបបំបាត់ការបង់ប្រាក់កំរៃទាំងឡាយណាដែលគ្មានមូលដ្ឋានច្បាប់ច្បាស់លាស់

ប្រាក់កំរៃក្រៅផ្លូវការយកលើពាណិជ្ជកម្មត្រីនៅកម្ពុជា អាចមានផលប៉ះពាល់ខ្លាំងលើចំនាយម៉ាឃីទីងសរុប ជាពិសេសលើការនាំចេញត្រី (Yim and McKenney 2003) ។ ថ្វីបើប្រាក់កំរៃហាក់ដូចតិចគួរសមទេតាមផ្លូវគោក ពីបឹងទន្លេសាបទៅភ្នំពេញ (គឺ ៩ដុល្លារ/តោនយកដោយក្រុមហ៊ុនវិនិយោគផ្លូវ និងកន្លែងកុងត្រូលមួយ) ប៉ុន្តែ ប្រាក់កំរៃនេះត្រូវបង់ឱ្យលុះត្រាណាតែវាមានលក្ខណៈស្របច្បាប់ និងមានការអនុញ្ញាត ។

### ៥) ធ្វើការស្រាវជ្រាវបន្ថែមលើតួនាទីនៃប្រព័ន្ធហិរញ្ញប្បទាន និងឥណទានក្រៅផ្លូវការក្នុងវិស័យនេសាទ

គំហើញក្នុងការសិក្សានេះ និងការសិក្សាលើកមុន (Yim and McKenney 2003) បង្ហាញថា ក្នុងទូទាំងវិស័យជលផល អ្នកនេសាទភាគច្រើនជំពាក់បំណុលពាណិជ្ជករ ហើយពាណិជ្ជករភាគច្រើនជំពាក់បំណុលអ្នកបែងចែក អ្នកលក់ដុំ ឬអ្នកនាំចេញ ។ តាមកិច្ចសន្យាឱ្យកំចី កូនបំណុលតាមធម្មតាត្រូវលក់ត្រីទាំងអស់ទៅឱ្យម្ចាស់បំណុលនៅកំរិតថ្លៃមួយដែលហាក់ដូចជាបញ្ចុះថោកបន្តិច ។ តួនាទីនៃឥណទាន/ហិរញ្ញប្បទានក្រៅផ្លូវការ និងទំនាក់ទំនងចងគ្នានៅក្នុងវិស័យជលផល គួរមានការសិក្សាបន្ថែម ។ ឧទាហរណ៏ តើទំនាក់ទំនងពាណិជ្ជកម្ម និងថ្លៃសំរាប់អ្នកនេសាទនិងពាណិជ្ជករជំពាក់បំណុលគេ វាមានលក្ខណះយ៉ាងណាបើធៀបនឹងអ្នកនេសាទ និងពាណិជ្ជករ មិនជំពាក់បំណុលគេ? តើពិតិមានទីផ្សារច្រើនថែមទៀត អាចជួយឱ្យអ្នកនេសាទអាចចរចាលក់ត្រីរបស់ខ្លួនបានថ្លៃល្អប្រសើរជាងនេះទេ ឬក៏ពតិមានបែបនេះគ្មានប្រយោជន៏អ្វីច្រើនទេ ដោយសារតែទំនាក់ទំនងចងភ្ជាប់គ្នាតាមលក្ខខណ្ឌឱ្យខ្ចីទុន? តើតំលាភាពអំពីអត្រាលក្ខខណ្ឌ និងសេវាផ្តល់កំចីអាចកែលំអរយ៉ាងណាបាន? តើប្រពន្ធ័ក្រៅផ្លូវការដែលមានស្រាប់ វាមានផលប្រយោជន៏អ្វីខ្លះ បើធៀបទៅនឹងឥណទានប្រភពស្ថាប័នផ្លូវការដែលអាចរកបាន? តើបច្ចុប្បន្នមានហានិភ័យ និងឧបសគ្គអ្វីខ្លះដែលរារាំងស្ថាប័នមីក្រូឥណទានផ្លូវការនានា ក្នុងការផ្តល់ឥណទានដល់ពាណិជ្ជករ និងអ្នកនេសាទ? គេត្រូវធ្វើការស្រាវជ្រាវនៅក្នុងចំនុចទាំងអស់នេះ ដើម្បីបង្កើនការយល់ដឹងពីប្រព័ន្ធហិរញ្ញប្បទានក្រៅផ្លូវការ វាយតំលៃពីចំណុចវិជ្ជមាន និងអវិជ្ជមាន និងរកឱ្យឃើញពីវិធានការនានាដែលអាចជួយកែលំអបាន ។

# ឯកសារយោង


Cambodia Daily, (16 October 2003), "Battle Over Ice Trade Heats Up in K. Chhnang", Vol. 27, Issue 59 (Phnom Penh)

Enterprise Development Cambodia (March 2002), *Cambodia Fisheries Sector Information System Design Initiative, Final Report*, (Phnom Penh)

Inland Fisheries Research and Development Institute of Cambodia (IFReDI) (2001), *Cambodia Fisheries Technical Paper Series, Volume III*, (Phnom Penh: Department of Fisheries)

Ouch, H. (1996), *Research on Activities at Fish Distribution Centers in Phnom Penh* (Thesis for Bachelor Degree Requirement, Royal University of Agriculture, Phnom Penh)

Touch, S. T. (1990), *Compiled Theme of Fishery Laws* (Phnom Penh: Department of Fisheries)

Touch, S. T. (2002), *The Inland and Marine Fish Trade of Cambodia* (Social, Economic, Political and Cultural Observation Unit, Council of Ministers)

Touch, S. T. (1992), *An Overview on Fish Marketing in Cambodia*

U. Kleih, P. Greenhalgh, and N. Oudwater, (2003), *A Guide to the Analysis of Fish Marketing Systems Using a Combination of Sub-sector Analysis and Sustainable Livelihoods Approach*, Post-Harvest Fisheries Research Programme – Project R7969, (United Kingdom: Department for International Development)

Van Zalinge, N., T. Nao, S. T. Touch, and L. Deap (2000), "Where there is water, there is fish? Cambodian fisheries issues in a Mekong River basin perspective", p. 37-48 in M. Ahmed and P. Hirsch (eds.), *Common property in the Mekong: issues of sustainability and subsistence*, (Manila: ICLARM Study Review 26)

Yim, C. and B. McKenney (2003), *Fish Exports from the Great Lake to Thailand: An Analysis of Trade Constraints, Governance, and the Climate for Growth*, Working Paper 27, (Phnom Penh: Cambodia Development Resource Institute)

# បញ្ជីឯកសារពិភាក្សារបស់ វបសអ


១. Kannan, K. P. (វិច្ឆិកា ១៩៩៥) ការកសាងសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់សំរាប់ប្រទេសកម្ពុជា: ការពិនិត្យឡើងវិញលើការអនុវត្តន៍នាពេលបច្ចុប្បន្ន និងការលើកមតិកែលំអ (ឯកសារពិភាក្សាលេខ ១) ច្បាប់ដែលបានបោះពុម្ពផ្សាយ ហើយផ្សព្វផ្សាយអស់ ។

២. McAndrew, John P. (មករា ១៩៩៦) ជំនួយហូរចូលជំនួយស្រពិចស្រពិល: ជំនួយសង្គ្រោះ និងអភិវឌ្ឍន៍ទ្វេ និងពហុភាគី ១៩៩២-៩៥ (ឯកសារពិភាក្សាលេខ ២) ច្បាប់ដែលបានបោះពុម្ព ហើយផ្សព្វផ្សាយអស់ ។

៣. Kannan, K. P. (មករា ១៩៩៧) ការកែទំរង់សេដ្ឋកិច្ច ការកែតម្រូវរចនាសម្ព័ន្ធ និងការអភិវឌ្ឍន៍កម្ពុជា (ឯកសារពិភាក្សាលេខ ៣) ច្បាប់ដែលបានបោះពុម្ពផ្សាយ ហើយផ្សព្វផ្សាយអស់ ។

៤. ជីម-ចរិយា ស្រ៊ុន-ពិធូ សូ-សុវណ្ណារិទ្ធ ចន-ម៉ាកឃិនឌ្រូ ងួន-សុគន្ធា ប៉ុន-ដូរីណា និងរ៉ូប៊ីន-ប៊ីដឺលវី (មិថុនា ១៩៩៨) ការរៀនសូត្រពីកម្មវិធីអភិវឌ្ឍន៍ជនបទក្នុងប្រទេសកម្ពុជា (ឯកសារពិភាក្សាលេខ ៤) ជាភាសាខ្មែរតំលៃ ៩.០០០រៀល ។

៥. Toshiyasu-Kato ច័ន្ទ-សុផល និងឡុង-វ៉ូ-ពិសិដ្ឋ (កញ្ញា ១៩៩៨) សមាហរណកម្មសេដ្ឋកិច្ចតំបន់សំរាប់ការអភិវឌ្ឍន៍ជានិរន្តរ៍ក្នុងប្រទេសកម្ពុជា (ឯកសារពិភាក្សាលេខ ៥) ជាភាសាខ្មែរ តំលៃ ៩.០០០រៀល ។

៦. Murshid, K. A. S. (ធ្នូ ១៩៩៨), សន្តិសុខស្បៀងនៅក្នុងសេដ្ឋកិច្ចអន្តរៈអាស៊ី: បទពិសោធន៍កម្ពុជា (ឯកសារពិភាក្សាលេខ ៦) ជាភាសាខ្មែរតំលៃ ៧.៥០០រៀល ។

៧. McAndrew, John P. (ធ្នូ ១៩៩៨) ការពឹងពាក់គ្នាទៅវិញទៅមកក្នុងយុទ្ធសាស្ត្រចិញ្ចឹមជីវិតគ្រួសារនៅក្នុងភូមិខ្មែរពីរ (ឯកសារពិភាក្សាលេខ ៧) ជាភាសាខ្មែរតំលៃ ៧.៥០០រៀល ។

៨. ច័ន្ទ-សុផល Martin-Godfrey, Toshiyasu-Kato ឡុង-វ៉ូ-ពិសិដ្ឋ Nina-Orlova, Per-Ronnås ទា-សាវ៉ាវ៉ា (មករា ១៩៩៩) ប្រទេសកម្ពុជា: បញ្ហាប្រឈមមុខនៃការបង្កើតការងារដែលមានផលិតភាព (ឯកសារពិភាក្សាលេខ ៨) ជាភាសាខ្មែរតំលៃ ៦.០០០រៀល ។

៩. តេង-យូតី ប៉ុន-ដូរីណា សូ-សុវណ្ណារិទ្ធ និង ចន-ម៉ាកឃិនឌ្រូ (មេសា ១៩៩៩) បទពិសោធន៍របស់សកម្មភាពសហគមន៍ដើម្បីអភិវឌ្ឍន៍សង្គមនៃអង្គការយូនីសេហ្វ (ឯកសារពិភាក្សាលេខ ៩) ជាភាសាខ្មែរតំលៃ ៤.៥០០រៀល ។

១០. Gorman, Siobhan, ជាមួយ ប៉ុន-ដូរីណា និង សុខ-ខេង (មិថុនា ១៩៩៩) បញ្ហាតួនាទីបុរស-ស្ត្រី និងការអភិវឌ្ឍន៍នៅក្នុងប្រទេសកម្ពុជា: ការពិនិត្យមើលជាទូទៅ (ឯកសារពិភាក្សាលេខ ១០) ជាភាសាខ្មែរតំលៃ ៤.៥០០រៀល ។

១១. ច័ន្ទ-សុផល និង សូ-សុវណ្ណារិទ្ធ (មិថុនា ១៩៩៩) ចំណាកពលកម្មកម្ពុជាទៅប្រទេសថៃ: ការប៉ាន់ស្មានជំហានដំបូង (ឯកសារពិគ្រោះលេខ ១១) ជាភាសាខ្មែរតំលៃ ៣.០០០រៀល ។

១២. ច័ន្ទ-សុផល Toshiyasu Kato ឡុង-វ៉ូពិសិដ្ឋ ទា-សាវ៉ាវ៉ា សូ-សុវណ្ណារិទ្ធ ហង់-ជួនណារ៉ុន កៅ-គឹមហួន និងជា-វ៉ុធណា (តុលា ១៩៩៩) ផលប៉ះពាល់នៃវិបត្តិហិរញ្ញវត្ថុអាស៊ីលើសេដ្ឋកិច្ចអន្តរកាលនៅបណ្តាប្រទេសអាស៊ីអគ្នេយ៍: ទស្សនៈកម្ពុជា (ឯកសារពិគ្រោះលេខ ១២) ជាភាសាខ្មែរតំលៃ ៤.៥០០រៀល ។

១៣. អ៊ុង-ប៊ុនឡេង (សីហា ២០០០) ការប្រែប្រួលតាមរដូវកាលនៃសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់នៅក្នុងប្រទេសកម្ពុជា (ឯកសារពិភាក្សាលេខ ១៣) ជាភាសាខ្មែរតំលៃ ៣.០០០រៀល ។

១៤. Toshiyasu-Kato Jeffrey A. Kaplan, ច័ន្ទ-សុផល និង រៀល-សុភាព (សីហា ២០០០) ប្រទេសកម្ពុជាៈ លើកកំពស់អភិបាលកិច្ចសំរាប់ការអភិវឌ្ឍន៍មានចិរន្តរភាព (ឯកសារពិភាក្សាលេខ ១៤) ជាភាសាខ្មែរ តំលៃ ៣.០០០រៀល ។

១៥. Toshiyasu Kato, ច័ន្ទ-សុផល Jeffrey A. Kaplan, (សីហា ២០០០) ជំនួយបច្ចេកទេស និងការអភិវឌ្ឍន៍សមត្ថភាពនៅក្នុងសេដ្ឋកិច្ចមួយដែលពឹងផ្អែកលើជំនួយៈ បទពិសោធន៍កម្ពុជា (ឯកសារពិភាក្សាលេខ ១៥) ជាខ្មែរតំលៃ ១០.០០០រៀល ។

១៦. ស៊ិក បូរ៉ក្ស (ធ្នូ ២០០០) កម្មសិទ្ធិ ការលក់ដូរ និងការប្រមូលផ្តុំដីធ្លីនៅកម្ពុជាៈ ការពិនិត្យវិភាគដោយត្រួសៗនូវទិន្នន័យទីពីរ និងទិន្នន័យដើម ដែលបានមកពីអង្កេតថ្មីៗចំនួនបួន (ឯកសារពិភាក្សាលេខ ១៦) ជាភាសាខ្មែរតំលៃ ៨.០០០រៀល ។

១៧. ច័ន្ទ-សុផល សូ-សុវណ្ណារិទ្ធ និងប៊ុន-ដូរីណា (មិថុនា ២០០១) ជំនួយបច្ចេកទេស និងការអភិវឌ្ឍន៍សមត្ថភាពនៅសាលាកសិកម្មព្រែកលៀប (ឯកសារពិភាក្សាលេខ ១៧) ជាភាសាខ្មែរ តំលៃ ៧.០០០រៀល ។

១៨. Martin Godfrey សូ-សុវណ្ណារិទ្ធ ទេព-សារ៉ាវី ប៊ុន-ដូរីណា Claude-Katz Sarthi-Acharya ស៊ីសុវត្ថិ-ឌួង-ចាន់តូ និង ហ៊ីងថូរ៉ាក់ស៊ី (តុលា ២០០១) ការសិក្សាអំពីទីផ្សារពលកម្មនៅកម្ពុជាៈ ការកាត់បន្ថយភាពក្រីក្រ ការលូតលាស់ និងការកែតំរូវចំពោះវិបត្តិ (ឯកសារពិភាក្សាលេខ ១៨) ជាភាសាខ្មែរ តំលៃ ៨.០០០រៀល ។

១៩. ច័ន្ទ-សុផល ទេព-សារ៉ាវី និង *Sarthi Acharya* (ខែធ្នូ ឆ្នាំ២០០១) ការកាន់កាប់ដីនៅកម្ពុជាៈ ការវិភាគលើទិន្នន័យចុងក្រោយ (ឯកសារពិភាក្សាលេខ ១៩) ជាភាសាខ្មែរ តំលៃ ៨.០០០រៀល ។

២០. សូ-សុវណ្ណារិទ្ធ រៀល-សុភាព អ៊ុច-ឧទេយ្យ ស៊ី-រត្នមុនី, Brett Ballard និង Sarthi Acharya (ខែមីនា ឆ្នាំ២០០២) ការវាយតំលៃសង្គមពាក់ព័ន្ធនឹងដីធ្លីនៅកម្ពុជា (ឯកសារពិភាក្សាលេខ ២០) ជាភាសាខ្មែរ តំលៃ ៨.០០០រៀល ។

២១. Bhargavi Ramamurthy ស៊ិក-បូរ៉ក្ស, Per Ronnås និង សុក-ហាច (ខែមីនា ឆ្នាំ២០០២) ប្រទេសកម្ពុជាឆ្នាំ១៩៩៩-២០០០: ការផ្តោតលើបញ្ហាដីធ្លី កំលាំងពលកម្ម និងការចិញ្ចឹមជីវិតនៅជនបទ (ឯកសារពិភាក្សាលេខ ២១) តំលៃ ៨.០០០រៀល ។

២២. ច័ន្ទ-សុផល និង Sarthi Acharya (ខែកក្កដា ឆ្នាំ២០០២) ការលក់ដូរដីធ្លីនៅកម្ពុជាៈ ការវិភាគទិន្នន័យនៃការផ្ទេរ និងការលក់ដូរដីធ្លី (ឯកសារពិភាក្សាលេខ ២២) ជាភាសាខ្មែរ តំលៃ ៨.០០០រៀល ។

២៣. Bruce McKenney និង ព្រុំ-តុលា (ខែកញ្ញា ឆ្នាំ២០០២) ធនធានធម្មជាតិ និងជីវភាពនៅតាមជនបទក្នុងប្រទេសកម្ពុជាៈ ការវាយតំលៃជាមូលដ្ឋាន (ឯកសារពិភាក្សាលេខ ២៣) ជាភាសាខ្មែរ តំលៃ ១០.០០០រៀល ជាអង់គ្លេស ១០ដុល្លារ ។

២៤. ច័ន្ទ-សុផល គីម-សេតារា និង Sarthi Acharya (ខែធ្នូ ឆ្នាំ២០០២) ដីធ្លី ជីវភាពជនបទ និងសន្តិសុខស្បៀងនៅកម្ពុជាៈ ទស្សនៈបានពីអង្កេតតាមមូលដ្ឋាន (ឯកសារពិភាក្សាលេខ ២៤) ជាភាសាខ្មែរតំលៃ ៦.០០០រៀល ជាអង់គ្លេស៧ដុល្លារ ។

២៥. ច័ន្ទ-សុផល និង Sarthi Acharya (ខែធ្នូ ឆ្នាំ២០០២) បញ្ហាប្រឈមចំពោះការចិញ្ចឹមជីវិតនៅជនបទ (ឯកសារពិភាក្សាលេខ២៥) ជាភាសាខ្មែរតំលៃ ៨.០០០រៀល ជាអង់គ្លេស ១០ដុល្លារ ។

២៦. Sarthi Acharya គីម-សេតារា ចាប-សុថារិទ្ធ និង មាច-យ៉ាឌី (ខែកញ្ញា ឆ្នាំ២០០៣) ការងារក្រៅកសិដ្ឋាន និងការងារមិនមែនកសិកម្មៈ ទស្សនៈស្តីពីការបង្កើតការងារនៅកម្ពុជា (ឯកសារពិភាក្សាលេខ២៦) ជាខ្មែរ ៧.០០០រៀល អង់គ្លេស ៥ដុល្លារ ។

២៧. យឹម-ជា និង Bruce McKenney (ខែធ្នូ ឆ្នាំ២០០៣) ការនាំចេញត្រីពីបឹងទន្លេសាបទៅប្រទេសថៃ (ឯកសារពិភាក្សាលេខ២៧) ជាភាសាខ្មែរតំលៃ ៧.០០០រៀល ជាអង់គ្លេស ១០ដុល្លារ ។

២៨. ព្រុំ-តុលា និង Bruce McKenney (ខែធ្នូ ឆ្នាំ២០០៣) ការធ្វើពាណិជ្ជកម្មផលព្រៃឈើនៅកម្ពុជាៈ ការប្រឈម ការគំរាមកំហែង និងឱកាសសំរាប់ពាណិជ្ជកម្មជ័រទឹក (ឯកសារពិភាក្សាលេខ២៨) ជាខ្មែរ ៧.០០០រៀល ជាអង់គ្លេស ១០ដុល្លារ ។

# ពាណិជ្ជកម្មត្រីក្នុងស្រុកៈ ករណីសិក្សានៃម៉ាឃីទីងត្រីពីបឹងទន្លេសាបទៅក្រុងភ្នំពេញ

ត្រីទឹកសាបដែលគេអាចចាប់បានជាង ៤០០.០០០តោនក្នុងមួយឆ្នាំៗ និងមានការបរិភោគយ៉ាងច្រើននៅក្នុងស្រុក គឺជាទំនិញលក់ដូរដ៏សំខាន់បំផុតមួយក្នុងប្រទេសកម្ពុជា ។ ត្រីស្រស់ និងត្រីកែច្នៃ មានធ្វើពាណិជ្ជកម្មយ៉ាងទូលំទូលាយនៅក្នុងប្រទេសកម្ពុជា ដោយពាណិជ្ជកម្មភាគច្រើនមានប្រភពចេញពីបឹងទន្លេសាប ។ ម៉ាឃីទីងត្រីមានបញ្ហាប្រឈម និងដំណាក់កាលជាច្រើន រួមទាំងការស្តុកទុក, ការលើកដាក់រៀបចំ, ការប្រមូលទុកឱ្យបានច្រើនគ្រប់គ្រាន់សំរាប់ដឹកជញ្ជូន, ការដឹកជញ្ជូន, ការចរចាលក់, និងការរក្សាគុណភាពជាដើម ។ អប្រសិទ្ធិភាពខាងម៉ាឃីទីងធ្វើឱ្យចំណាយកើនឡើង ដែលអាចប៉ះពាល់ជាអវិជ្ជមានដល់ចំណូលរបស់អ្នកលក់ត្រី និងអ្នកនេសាទព្រមទាំងអ្នកផ្សេងទៀតដែលប្រកបការងារក្នុងវិស័យនេះ ។

ដើម្បីវាយតំលៃពីលក្ខខណ្ឌបច្ចុប្បន្ននៃការលក់ដូរត្រីទឹកសាប ការសិក្សានេះបានពិនិត្យពីពាណិជ្ជកម្មត្រីចាប់តាំងពីកន្លែងឡើងត្រីសំខាន់ៗពីរកន្លែងនៅបឹងទន្លេសាប រហូតដល់ទីផ្សារលក់រាយនៅក្រុងភ្នំពេញ ដែលជាផ្លូវពាណិជ្ជកម្មត្រីក្នុងស្រុកធំជាងគេបំផុត ។ ការស្រាវជ្រាវនេះផ្អែកលើប្រហែល ៦០បទសំភាសន៍ពាក់កណ្តាលរៀបរយធ្វើជាមួយអ្នកនេសាទ ពាណិជ្ជករ អ្នកបែងចែក ម្ចាស់មណ្ឌលបែងចែក អ្នកលក់រាយ និងមន្ត្រីរាជការ ។ លើសពីនេះទៀត មានការធ្វើដំណើរ "តាមរថយន្តដឹកត្រី" ពីរលើក ចាប់ពីកន្លែងឡើងត្រីរហូតដល់មណ្ឌលបែងចែក ដើម្បីសង្កេតផ្ទាល់ពីលក្ខខណ្ឌពាណិជ្ជកម្ម និងផ្ទៀងផ្ទាត់លើពតិមានប្រមូលបាននៅក្នុងបទសំភាសន៍ ។

---

លោក យឹម ជា គឺជាអ្នកស្រាវជ្រាវនៅ វបសអ ហើយ Bruce McKenney គឺជាអ្នកគ្រប់គ្រងកម្មវិធីធនធានធម្មជាតិ និងបរិស្ថានរបស់ វបសអ ។

**វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា**

**20.000 រៀល**

អាសយដ្ឋានលេខ ៥៦ ផ្លូវ៣១៥ ខ័ណ្ឌទួលគោក ភ្នំពេញ កម្ពុជា
ប្រអប់សំបុត្រលេខ ៦២២ ភ្នំពេញ កម្ពុជា
**ទូរស័ព្ទ: (៨៥៥-២៣) ៨៨១-៧០១/៨៨១-៩១៦/៨៨១-៣៨៤/៨៨៣-៦០៣ ទូរស័ព្ទ/ទូរសារ: (៨៥៥-២៣) ៨៨០-៧៣៤**
អ៊ីមែល: cdri@camnet.com.kh website: http://www.cdri.org.kh